# ៥. យុទ្ធសាស្ត្រតាមវិស័យ

## ៥.១ ផែនការអភិវឌ្ឍន៍ដើម្បីឈានទៅសំរេចយុទ្ធសាស្ត្រ

យោងតាមយុទ្ធសាស្ត្រខាងលើ ត្រូវចាត់វិធានការមួយចំនួននៅតាមវិស័យផ្សេងៗ ។ ជំពូកនេះឆ្លុះបញ្ចាំងពីវិធានការដែលត្រូវស្នើឡើងក្នុងផែនការអភិវឌ្ឍន៍តាមវិស័យ ស្របតាមយុទ្ធសាស្ត្រនីមួយៗ ។

**១. ផែនការអភិវឌ្ឍន៍តាមវិស័យតាមយុទ្ធសាស្ត្រទី១ : "ការលើកកំពស់ទេសចរណ៍ដោយយកចិត្តទុកដាក់លើភ្ញៀវទេសចរដែលមានកំរិតចំណាយខ្ពស់"**

ផែនការអភិវឌ្ឍន៍ទេសចរណ៍ គឺជាផ្នែកដ៏សំខាន់របស់យុទ្ធសាស្ត្រនេះដែលពាក់ព័ន្ធទៅនឹងហេដ្ឋារចនាសម្ព័ន្ធមួយចំនួនដូចជា មធ្យោបាយដឹកជញ្ជូន និងអគ្គីសនី និងការគ្រប់គ្រងការអភិវឌ្ឍន៍ ។ ដើម្បីបង្កើតក្រុងទេសចរណ៍គុណភាពមួយ ផែនការអភិវឌ្ឍន៍ទេសចរណ៍ត្រូវមានគោលដៅបង្កើតតំបន់ទេសចរណ៍គុណភាពតាមបរិបទប្រវត្តិសាស្ត្រ និងវប្បធម៌អង្គរ ។ សៀមរាបពុំទាន់ត្រូវបានអភិវឌ្ឍន៍រួចរាល់ដើម្បីទាក់ទាញប្រភេទភ្ញៀវទេសចរផ្សេងៗ ដែលមានបំណងស្វែងយល់ស៊ីជំរៅលើប្រវត្តិសាស្ត្រ និងវប្បធម៌អង្គរនៅឡើយ ។ ទីផ្សារទេសចរណ៍អន្តរជាតិចាត់ទុកក្រុងសៀមរាប/អង្គរជាក្រុងពុំទាន់មានសុវត្ថិភាពគ្រប់គ្រាន់សំរាប់ភ្ញៀវទេសចរបុគ្គលដើរកំសាន្តឡើយ ។ កត្តាមួយក្នុងចំណោមកត្តានានា នោះគឺថាទីផ្សារ និងការលើកកំពស់ភាពជាដៃគូរដ្ឋ-ឯកជននៅមានកំរិតខ្សោយ ។ យោងតាមយុទ្ធសាស្ត្រទី១នេះ មានការស្នើឡើងនូវវិធានការទាំងឡាយដូចខាងក្រោម :

**១) អភិវឌ្ឍតំបន់ទេសចរណ៍ និងផ្លូវផ្សេងៗសំរាប់ទស្សនាកំសាន្ត**

ធ្វើការប្រើប្រាស់ឱ្យបានពេញលេញនូវធនធានទេសចរណ៍សំខាន់ៗក្នុងក្រុងសៀមរាប/អង្គរ ។ ត្រូវតែបង្កើតតំបន់ទេសចរណ៍៤ ជុំ និងត្រូវបញ្ចូលតំបន់ទាំងនោះទៅក្នុងផ្លូវសំរាប់ទស្សនាកំសាន្ត ។

- តំបន់បេតិកភណ្ឌអង្គរ : ធ្វើផែនការ និងការគ្រប់គ្រងរួម
- តំបន់ទេសចរណ៍វប្បធម៌ និងសោភ័ណភាពក្រុង : លើកកំពស់សោភ័ណភាព និងបរិយាកាស
- តំបន់ជនបទ និងតំបន់ទន្លេសាប : ទេសចរណ៍តាមភូមិ/ទេសចរណ៍ធម្មជាតិសំរាប់ឱ្យភ្ញៀវទេសចរមានទំនាក់ទំនងជាមួយវប្បធម៌
- តំបន់រមណីយដ្ឋាននៅឆ្ងាយពីប្រាសាទអង្គរ : ត្រូវដាក់បញ្ចូលទៅក្នុងផ្លូវទស្សនាកំសាន្តរបស់ភ្ញៀវ ។

ដើម្បីអភិវឌ្ឍន៍តំបន់ទេសចរណ៍តាមតំបន់បេតិកភណ្ឌអង្គរ ក្រុមសិក្សាស្នើឱ្យមានការអភិវឌ្ឍន៍មធ្យោបាយធ្វើដំណើរក្នុងវិស័យមធ្យោបាយធ្វើដំណើរ និងស្នើឱ្យធ្វើការកែលំអលទ្ធភាពធ្វើដំណើរទៅកាន់តំបន់ប្រាសាទផ្សេងៗទៀតដែល ស្ថិតនៅឆ្ងាយពីរមណីយដ្ឋានអង្គរ ។ ទាក់ទងនឹងសោភ័ណភាពក្រុង និងតំបន់ទេសចរណ៍វប្បធម៌ យុទ្ធសាស្ត្រទី១ នេះមានទំនាក់ទំនងគ្នាជាមួយនឹងយុទ្ធសាស្ត្រទី២ ។ ការបំភ្លឺផ្លូវ និងបេតិកភណ្ឌអង្គរត្រូវបានស្នើឡើងក្នុងវិស័យអគ្គិសនី ។

**២) ផ្តល់ឱ្យភ្ញៀវទេសចរនូវបទពិសោធន៍ជាក់ស្តែងពីវប្បធម៌ ប្រវត្តិសាស្ត្រ សិល្បៈ និងលក្ខណៈខ្មែរដ៏សម្បូរបែប :** បង្កើតផ្លូវសំរាប់ដំណើរកំសាន្តជាក់លាក់ និងប្រមូលធនធានវប្បធម៌សំខាន់ៗ ដូចជាពិធីបុណ្យ ផ្ទះជនជាតិដើម និងទំនៀមទំលាប់នៅមូលដ្ឋាន ។

**៣) កែលំអសេវាកម្ម និងបដិសណ្ឋារកិច្ចដើម្បីឱ្យការស្នាក់នៅរបស់ភ្ញៀវទេសចរប្រកបដោយភាពរីករាយ :** ព័ត៌មានអំពីទេសចរណ៍មធ្យោបាយដឹកជញ្ជូនក្នុងស្រុក និងអំពីការនាំភ្ញៀវទេសចរ ។

**៤) ពង្រឹងទីផ្សារ និងការលើកកំពស់ទេសចរណ៍ :** ត្រូវតែធ្វើការពង្រឹងទីផ្សារ និងការលើកកំពស់ តាមរយៈភាពជាដៃគូរដ្ឋ-ឯកជន ដើម្បីទាក់ទាញភ្ញៀវទេសចរដែលមានកិរិតចំណាយខ្ពស់ ។

**២. ផែនការអភិវឌ្ឍន៍តាមវិស័យតាមយុទ្ធសាស្ត្រទី២ : "លើកកំពស់ផលប្រយោជន៍មូលដ្ឋានតាមរយៈទេសចរណ៍ឱ្យដល់កំរិតអតិបរមា"**

ការពង្រីកកសិកម្ម និងការលើកកំពស់ផលិតផលក្នុងស្រុក គឺជាផ្នែកដ៏សំខាន់នៃយុទ្ធសាស្ត្រទី២ ដែលមានទំនាក់ទំនងជាមួយនឹងការគ្រប់គ្រងការអភិវឌ្ឍន៍ ។ ការបង្កើតនិមិត្តសញ្ញាអង្គរសំរាប់លើកកំពស់ការផ្គត់ផ្គង់របស់មូលដ្ឋានទៅក្នុងទីផ្សារទេសចរណ៍ត្រូវបានស្នើឡើង ។ ជាមួយគ្នានេះដែរ គេត្រូវយកចិត្តទុកដាក់ពិសេសទៅលើតំបន់ជនបទ ព្រមទាំងស្នើឱ្យគិតគូរដាក់បញ្ចូលសេដ្ឋកិច្ចជនបទទៅក្នុងវិស័យទេសចរណ៍តាមរយៈភូមិ១ ផលិតផល១ និងការអភិវឌ្ឍន៍ភូមិផលិតកម្ម ។

១) បង្កើតនិមិត្តសញ្ញាអង្គរសំរាប់ការផ្គត់ផ្គង់ពីមូលដ្ឋានឱ្យបានកាន់តែច្រើនឡើង

២) បញ្ចូលសេដ្ឋកិច្ចមូលដ្ឋានទៅក្នុងវិស័យទេសចរណ៍ ។

ដើម្បីបង្កើតនិមិត្តសញ្ញាផលិតផលអង្គរ ភាពជាដៃគូរវាងសាធារណៈ-ឯកជនគឺជាការចាំបាច់ ។ ទីផ្សារពេលយប់ដែលបានស្នើឡើងក្នុងវិស័យអភិវឌ្ឍន៍ទេសចរណ៍ក៏មានទំនាក់ទំនងទៅនឹងភាពជាដៃគូនេះដែរ ។

**៣. ផែនការអភិវឌ្ឍន៍តាមវិស័យតាមយុទ្ធសាស្ត្រទី៣ : "ការធ្វើឱ្យសៀមរាបកាន់តែមានការទាក់ទាញបន្ថែមទៀតដល់ភ្ញៀវទេសចរ"**

ដើម្បីធ្វើឱ្យសំរេចក្រុងមួយដែលមានចំនួនប្រជាជន ស្របទៅនឹងបរិយាកាសអង្គរ ផែនការអភិវឌ្ឍន៍ក្រុងមានមុខងារសំខាន់ ដែលមានការគាំទ្រពីវិស័យហេដ្ឋារចនាសម្ព័ន្ធ និងការគ្រប់គ្រងការអភិវឌ្ឍន៍ ។ ខាងក្រោមនេះគឺជាយុទ្ធសាស្ត្រនានាក្នុងផែនការអភិវឌ្ឍន៍ក្រុង ។

១) តំរង់ទិសលើការពង្រីកក្រុង ដើម្បីបង្កើតក្រុងទំនើបមួយ

២) អភិវឌ្ឍតំបន់កណ្តាលក្រុង សំរាប់ធ្វើជាច្រកយុទ្ធសាស្ត្រសំរាប់លើកកំពស់ការទាក់ទាញភ្ញៀវទេសចរ

៣) ការពង្រីកក្រុងដោយផ្អែកលើហេដ្ឋារចនាសម្ព័ន្ធ

ដើម្បីតំរង់ទិសលើការពង្រីកក្រុងដើម្បីបង្កើតទីក្រុងទំនើបមួយ ការបង្កើតបណ្តាញផ្លូវក្នុងក្រុង និងការលើកកំពស់ប្រព័ន្ធបង្ហូរទឹក គឺជាវិធានដ៏សំខាន់ ។ ដើម្បីធ្វើក្រុងមានការទាក់ទាញ ផ្លូវសំរាប់ដើរ និងការបំភ្លឺតាមផ្លូវគឺជាការចាំបាច់ ។ ការធ្វើផែនការក្រុងក៏អាចជួយដល់ណែនាំដល់ការពង្រីកក្រុង ព្រមទាំងចូលរួមពង្រឹងផែនការប្រើប្រាស់ដីធ្លី និងសមត្ថភាពធ្វើផែនការគ្រប់គ្រាន់ ។ ដើម្បីធ្វើឱ្យផែនការក្រុងមានប្រសិទ្ធភាព ការកែលំអការគ្រប់គ្រង ដូចជាគណៈកម្មការអភិវឌ្ឍន៍ គឺជាការចាំបាច់ សំរាប់វាយតំលៃគំរោងអភិវឌ្ឍន៍ ដើម្បីឱ្យដឹងថាតើគំរោងនោះស្របទៅតាមផែនការក្រុងឬយ៉ាងណា ។ ការគ្រប់គ្រងព័ត៌មានក៏ជាតំរូវការចាំបាច់ផងដែរ ដើម្បីពង្រឹងផែនការប្រើប្រាស់ដីធ្លីដោយផ្អែកលើព័ត៌មានសមស្រប ។

## ៤. ផែនការអភិវឌ្ឍន៍តាមវិស័យតាមយុទ្ធសាស្ត្រទី៤ : "ការធ្វើឱ្យក្រុងកាន់តែមាននិរន្តរភាពខាងបរិស្ថាន"

ដើម្បីធ្វើឱ្យក្រុងមួយមានការគិតគូរដល់បរិស្ថាន យុទ្ធសាស្ត្រសមស្របមួយគឺជាការចាំបាច់។ យុទ្ធសាស្ត្រនេះមានៈ ការគ្រប់គ្រងបរិស្ថាន ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ ការគ្រប់គ្រង និងហិរញ្ញវត្ថុ។ វិស័យគ្រប់គ្រងបរិស្ថានលើកឡើងវិធីសាស្ត្រមួយចំនួនដូចខាងក្រោម ដោយធ្វើយ៉ាងណាឱ្យសមស្របទៅនឹងបេតិកភណ្ឌ និងលក្ខណៈអង្គរ និងសំរាប់កាត់បន្ថយធនធាន និងថាមពល។

១) ការកសាងសមត្ថភាពស្ថាប័ន

២) ការលើកកំពស់ការយល់ដឹងអំពីបរិស្ថាន

៣) ផ្តល់ហិរញ្ញវត្ថុដើម្បីការអភិរក្សបរិស្ថាន

៤) ធ្វើផែនការអភិវឌ្ឍន៍ដោយយកចិត្តទុកដាក់ដល់បរិស្ថាន

វិធីសាស្ត្រខាងលើមិនអាចអនុវត្តដាច់ដោយឡែកតែមួយបានទេ ផ្ទុយទៅវិញត្រូវផ្គុបផ្សំជាមួយនឹងវិស័យទេសចរណ៍ ការអភិវឌ្ឍន៍ក្រុង ការគ្រប់គ្រង និងហិរញ្ញវត្ថុ ដូចមានបង្ហាញក្នុងតារាងខាងក្រោម។

| | *ភាពសមស្របទៅនឹងបេតិកភណ្ឌ និងលក្ខណៈអង្គរ* | *ការកាត់បន្ថយធនធាន និងថាមពល* |
|---|---|---|
| ទេសចរណ៍ | ការគ្រប់គ្រងរមណីយដ្ឋានអង្គរ (TO-6) | |
| ការអភិវឌ្ឍន៍ក្រុង | ការគ្រប់គ្រងតំបន់បៃតងតាមរយៈផែនការប្រើប្រាស់ដីធ្លី | |
| មធ្យោបាយដឹកជញ្ជូន | ការដឹកជញ្ជូនដោយមិនបំពុលបរិស្ថានតាមរមណីយដ្ឋានបេតិកភណ្ឌ(TR-8, 9) | |
| ធនធានទឹក/ប្រព័ន្ធបង្ហូរទឹកភ្លៀង និងសំណល់រាវ | ការគ្រប់គ្រងការយកទឹកក្រោមដី (W-1,2) | ការធ្វើប្រព្រឹត្តិកម្មសំណល់រាវ |
| ការគ្រប់គ្រងសំណល់រឹង | | ការគ្រប់គ្រងសំណល់រឹង<br>កន្លែងចាក់សំរាមអនាម័យ (SW-3) |
| ថាមពល | | ការគ្រប់គ្រងម៉ាស៊ីនភ្លើងឯកជន (P-9) |
| ការគ្រប់គ្រងការអភិវឌ្ឍន៍/ហិរញ្ញវត្ថុមូលដ្ឋាន | ការពង្រឹងច្បាប់ និងបទដ្ឋានទាក់ទងនឹងការយកទឹកក្រោមដី និងម៉ាស៊ីនភ្លើងរបស់បុគ្គល<br>ភាពជាដៃគូរវាងរដ្ឋ-ឯកជនសំរាប់ការគ្រប់គ្រងសំណល់រឹង<br>ការពង្រឹងមូលដ្ឋានហិរញ្ញវត្ថុ<br>ការអភិវឌ្ឍន៍ធនធានមនុស្សទាក់ទងនឹងការគ្រប់គ្រងព័ត៌មានអំពីការបូមទឹកក្រោមដី និងម៉ាស៊ីនភ្លើងរបស់បុគ្គល | |
| ការផ្តល់អំណាចដល់មូលដ្ឋាន | រស់នៅជាមួយនឹងរមណីយដ្ឋានអង្គរ (TR-8, 9) | |

**កំណត់សំគាល់ :** ចំនួនក្នុងវង់ក្រចកតំណាងចំនួនគំរោងដែលនឹងពិភាក្សានៅផ្នែកខាងក្រោម។

## ៥. ផែនការអភិវឌ្ឍន៍តាមវិស័យតាមយុទ្ធសាស្ត្រទី៥ : "ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសំរាប់ភ្ញៀវទេសចរ និងប្រជាជន"

ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធត្រូវអនុវត្តចំពោះវិស័យ៥ គឺមធ្យោបាយដឹកជញ្ជូន ធនធាន និងការផ្គត់ផ្គង់ទឹក ការគ្រប់គ្រងសំណល់រឹង ប្រព័ន្ធបង្ហូរទឹកភ្លៀង និងសំណល់រាវ និងថាមពល។ ហេដ្ឋារចនាសម្ព័ន្ធជួយដល់វិស័យទេសចរណ៍ ក្រុងដែលមានការទាក់ទាញ និងបរិស្ថាន ដូចមានលើកឡើងក្នុងយុទ្ធសាស្ត្រ១-៣។

## ៦. ផែនការអភិវឌ្ឍន៍តាមវិស័យតាមយុទ្ធសាស្ត្រទី៦ : "ការពង្រឹងរដ្ឋបាល និងហិរញ្ញវត្ថុមូលដ្ឋាន"

រដ្ឋបាល និងហិរញ្ញវត្ថុមូលដ្ឋានរួមមានការគ្រប់គ្រងការអភិវឌ្ឍន៍ ហិរញ្ញវត្ថុមូលដ្ឋាន និងការផ្តល់សិទ្ធិអំណាចដល់សហគមន៍។ វិស័យទាំងនេះក៏ជួយដល់វិស័យទេសចរណ៍ ក្រុងដែលមានការទាក់ទាញ និងបរិស្ថាន ដូចមានលើកឡើងក្នុងយុទ្ធសាស្ត្រ ១-៣ដែរ ។ វិធីសាស្ត្រសំខាន់រួមមានដូចខាងក្រោម :

១) ការធ្វើឱ្យមានភាពរលូននូវរដ្ឋបាលមូលដ្ឋាន

២) ភាពជាដៃគូថ្មីរវាងជំនួញ ប្រជាជន និងរដ្ឋាភិបាល

៣) ពង្រឹងមូលដ្ឋានហិរញ្ញវត្ថុមូលដ្ឋានសំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព

៤) ពង្រឹងការអនុវត្តន៍ច្បាប់ និងបទដ្ឋានច្បាប់ផ្សេងៗ

៥) ការអភិវឌ្ឍន៍ធនធានមនុស្សនៅមូលដ្ឋាន

តារាងខាងក្រោមគឺជាសេចក្តីសង្ខេបយុទ្ធសាស្ត្រនៃផែនការអភិវឌ្ឍន៍តាមវិស័យ

## តារាង ១១ : យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍន៍តាមវិស័យ : ខ្លឹមសាររួម

| ចក្ខុវិស័យជាយុទ្ធសាស្ត្រ | | | ផែនការអភិវឌ្ឍន៍តាមវិស័យ | | |
|---|---|---|---|---|---|
| គោលបំណង | ចក្ខុវិស័យ : ក្រុងសៀមរាប/អង្គរឆ្នាំ ២០២០ | យុទ្ធសាស្ត្រ | សេដ្ឋកិច្ច ការអភិវឌ្ឍន៍ និងបរិស្ថានក្រុង | ហេដ្ឋារចនាសម្ព័ន្ធ | រដ្ឋបាល និងហិរញ្ញវត្ថុ |
| ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពដល់ឆ្នាំ ២០២០ តាមរយៈ:<br>• ការលើកកំពស់ទេសចរណ៍តាមវិធីចីរភាព<br>• លើកកំពស់ និងពង្រីកសេដ្ឋកិច្ចមូលដ្ឋានទាក់ទងនឹងទេសចរណ៍<br>• អភិរក្សបរិស្ថាន<br>• ពង្រឹងសមត្ថភាព | <u>ក្រុងទេសចរណ៍គុណភាព</u><br>• ក្រុងនៃវប្បធម៌ ប្រវត្តិសាស្ត្រ និងសិល្បៈ<br>• មូលដ្ឋានសំរាប់ទេសចរណ៍រមណីយដ្ឋានអង្គរ<br>• សេវាកម្មប្រកបដោយគុណភាពសំរាប់ការស្នាក់នៅដោយរីករាយ | ១. លើកកំពស់ទេសចរណ៍ដោយយកចិត្តទុកដាក់ភ្ញៀវដែលមានកំរិតចំណាយខ្ពស់ | <u>អភិវឌ្ឍទេសចរណ៍</u><br>• អភិវឌ្ឍន៍ និងពង្រីកផ្លូវធ្វើដំណើរឱ្យបានទូលំទូលាយ<br>– តំបន់ឧទ្យានប្រវត្តិសាស្ត្រអង្គរ<br>– តំបន់ទេសចរណ៍វប្បធម៌ និងសោភ័ណភាពក្រុង<br>– តំបន់ជនបទ និងទន្លេសាប<br>– តំបន់រមណីយដ្ឋានទៅឆ្ងាយពីអង្គរ<br>• លើកកំពស់កំរិតវប្បធម៌<br>• កែលំអសេវាកម្ម<br>• ពង្រឹងទីផ្សារ និងការផ្សព្វផ្សាយ | <u>មធ្យោបាយដឹកជញ្ជូន</u><br>• លទ្ធភាពចូលតំបន់បេតិកភណ្ឌ<br>• ការដឹកជញ្ជូនក្នុងឧទ្យានបេតិកភណ្ឌអង្គរ<br><u>ថាមពល</u><br>• បំភ្លឺសំរាប់រមណីយដ្ឋានអង្គរ | <u>ការគ្រប់គ្រងការអភិវឌ្ឍន៍</u><br>• ភាពជាដៃគូរវាងរដ្ឋ-ឯកជនសំរាប់លើកកំពស់ទីផ្សារ និងផ្សព្វផ្សាយទេសចរណ៍ |
| | | ២. ពង្រីកផលប្រយោជន៍មូលដ្ឋានដែលបានពីទេសចរណ៍ | <u>ការពង្រីកកសិកម្ម និងការផ្សព្វផ្សាយផលិតផលក្នុងស្រុក</u><br>• និមិត្តសញ្ញាអង្គរសំរាប់ការផ្គត់ផ្គង់ផលិតផលក្នុងស្រុកឱ្យបានច្រើនឡើង<br>• និពន្ធបញ្ចូលសេដ្ឋកិច្ចមូលដ្ឋានទៅក្នុងវិស័យទេសចរណ៍<br><u>ការអភិវឌ្ឍន៍ទេសចរណ៍</u><br>• ទីផ្សារទេសចរណ៍ពេលយប់ | | <u>ការគ្រប់គ្រងការអភិវឌ្ឍន៍</u><br>• ភាពជាដៃគូរវាងរដ្ឋ-ឯកជនសំរាប់មជ្ឈមណ្ឌលលើកកំពស់ផលិតផលអង្គរ |
| | <u>ក្រុងដែលមានមនុស្សរស់នៅក្នុងបរិយាកាសរម្យ</u><br>• បរិយាកាសល្អ<br>• ស្អាត សុវត្ថិភាព ផាសុកភាព និងងាយស្រួលធ្វើដំណើរកំសាន្ត<br>• ក្រុងមានចំនួនមនុស្សសមស្រប | ៣. ធ្វើឱ្យក្រុងកាន់តែមានការទាក់ទាញដល់ភ្ញៀវទេសចរ | <u>ការអភិវឌ្ឍន៍ក្រុង</u><br>• ការពង្រីកក្រុងតាមគោលដៅដើម្បីបង្កើតជាក្រុងទំនើប<br>• កែលំអមជ្ឈមណ្ឌលក្រុង<br>• អភិវឌ្ឍទីលានហេដ្ឋារចនាសម្ព័ន្ធសំរាប់តំរង់ទិសការពង្រីកក្រុង | <u>មធ្យោបាយដឹកជញ្ជូន</u><br>• បណ្តាញផ្លូវសំរាប់តំរង់ការពង្រីកក្រុង<br>• ផ្លូវដើរកំសាន្ត និងសោភ័ណភាពក្រុង<br>• សុវត្ថិភាពក្រុង<br><u>ប្រព័ន្ធបង្ហូរសំណល់រាវ និងទឹកភ្លៀង</u><br>• ប្រព័ន្ធបង្ហូរទឹកភ្លៀងសំរាប់តំរង់ការពង្រីកក្រុង<br><u>ថាមពល</u><br>• ភ្លើងតាមផ្លូវ | <u>ការគ្រប់គ្រងការអភិវឌ្ឍន៍</u><br>• គណៈកម្មការអភិវឌ្ឍន៍សំរាប់ត្រួតពិនិត្យការអភិវឌ្ឍន៍តាមទស្សនៈផែនការក្រុង<br>• ពង្រឹងផែនការប្រើប្រាស់ដី ការចុះបញ្ជីយានយន្ត និងច្បាប់ចរាចរណ៍<br>• ការអភិវឌ្ឍន៍ធនធានមនុស្សសំរាប់គ្រប់គ្រងព័ត៌មាន |

| | | | | | |
|---|---|---|---|---|---|
| | **<u>ក្រុងដែលយកចិត្តទុកដាក់លើ បរិស្ថាន</u>**<br>● សារកសមាទៅនឹងបេតិកភណ្ឌនិងលក្ខណៈអង្គរ<br>● សន្សំធនធាន និងថាមពល | ៤.<br>**ធ្វើឱ្យក្រុងកាន់តែមាននិរន្តរភាពខាងបរិស្ថាន** | **<u>ការគ្រប់គ្រងបរិស្ថាន</u>**<br>● កសាងសមត្ថភាពសំរាប់ការគ្រប់គ្រងបរិស្ថាន<br>● ការលើកកំពស់ការយល់ដឹងបរិស្ថាន<br>● ការផ្តល់ហិរញ្ញវត្ថុសំរាប់ការអភិរក្សបរិស្ថាន<br>● ផែនការអភិវឌ្ឍន៍ដោយយកចិត្តទុកដាក់ដល់បរិស្ថាន | **<u>មធ្យោបាយដឹកជញ្ជូន</u>**<br>● ការដឹកជញ្ជូនដោយមានការគិតគូរពីបរិស្ថានក្នុងតំបន់បេតិកភណ្ឌអង្គរ<br>**<u>ធនធានទឹក និងការផ្គត់ផ្គង់ទឹក</u>**<br>● ការគ្រប់គ្រងលើការបូមទឹកក្រោមដី<br>● ការប្រើប្រាស់ទឹកដោយគិតគូរពីបរិស្ថាន<br>**<u>ប្រព័ន្ធបង្ហូរទឹកភ្លៀង និងសំណល់</u>**<br>● ការធ្វើប្រព្រឹត្តិកម្មសំណល់រាវ<br>**<u>ការគ្រប់គ្រងសំណល់រឹង</u>**<br>● កន្លែងចាក់សំរាមអនាម័យ និងការកាត់បន្ថយសំណល់រឹង<br>**<u>ថាមពល</u>**<br>● ការកាត់បន្ថយម៉ាស៊ីនភ្លើងឯកជន | **<u>ការគ្រប់គ្រងការអភិវឌ្ឍន៍</u>**<br>● គណៈកម្មការសំរាប់វាយតំលៃតំរោងតាមទស្សនៈបរិស្ថាន<br>● ពង្រឹងច្បាប់ និងបទដ្ឋានច្បាប់សំរាប់ការបូមទឹកក្រោមដី និងម៉ាស៊ីនភ្លើងប្រើម៉ាស៊ូត<br>● ពង្រឹងហិរញ្ញវត្ថុសំរាប់បរិស្ថាន<br>● ភាពជាដៃគូរដ្ឋ-ឯកជនដើម្បីគ្រប់គ្រងសំណល់រឹង<br>● ការអភិវឌ្ឍន៍ធនធានមនុស្សសំរាប់គ្រប់គ្រងព័ត៌មាន<br>**<u>ការផ្តល់សិទ្ធិអំណាចដល់សហគមន៍</u>**<br>● ការសំអាតរបស់ប្រជាជនជាមួយនឹងរហូតដល់អង្គរ |
| | *ក្រុងស្អាតនិងមានសុវត្ថិភាព ដោយផ្អែកលើប្រវត្តិសាស្ត្រ សិល្បៈ និងលក្ខណៈខ្មែរ*<br>● *បង្ហាញពីអតីតកាលរុងរឿងសម័យអង្គរដើម្បីជាគំរូទៅទសវត្សរ៍ទី២១សំរាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព និងភាពសម្បូរបែបខាងវប្បធម៌*<br>● *ការទាក់ទាញដោយសារវប្បធម៌ទៅកាន់អាស៊ីអាគ្នេយ៍* | ៥.<br>**ពង្រឹងហេដ្ឋារចនាសម្ព័ន្ធ សំរាប់ភ្ញៀវទេសចរណ៍ និងប្រជាជន** | | **<u>មធ្យោបាយដឹកជញ្ជូន</u>**<br>● បណ្តាញផ្លូវគ្រប់គ្រាន់សំរាប់ភ្ញៀវ និងប្រជាជន<br>**<u>ធនធានទឹក និងការផ្គត់ផ្គង់ទឹក</u>**<br>● ការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តរភាព និងការផ្គត់ផ្គង់ទឹក<br>**<u>ការគ្រប់គ្រងសំណល់រឹង</u>**<br>● ការធ្វើឱ្យក្រុងក្លាយជាទីស្រលាញ់<br>**<u>ប្រព័ន្ធបង្ហូរទឹកភ្លៀង និងសំណល់រាវ</u>**<br>● ប្រព័ន្ធបង្ហូរសំណល់រាវ និងទឹកភ្លៀងប្រកបដោយនិរន្តរភាពដើម្បីអនាម័យ និងសោភ័ណភាពក្រុង<br>**<u>ថាមពល</u>**<br>● ថាមពលដែលអាចទុកចិត្តបានដោយបង្កបន្ទុកបរិស្ថានតិចតួច | **<u>ការគ្រប់គ្រងការអភិវឌ្ឍន៍</u>**<br>● ការធ្វើផែនការ ការគ្រប់គ្រង និងការត្រួតពិនិត្យគំរោង<br>**ការផ្តល់ហិរញ្ញវត្ថុដល់មូលដ្ឋាន**<br>● មូលនិធិអភិវឌ្ឍន៍សៀមរាប |

| | | | | | |
|---|---|---|---|---|---|
| | | ៦. ពង្រឹងរដ្ឋបាល និងហិរញ្ញវត្ថុមូលដ្ឋាន | | | <u>ការគ្រប់គ្រងការអភិវឌ្ឍន៍</u><br>● ធ្វើឱ្យល្អនូវរដ្ឋបាលមូលដ្ឋានដោយមានតម្លាភាព និងការទទួលខុសត្រូវ<br>● ភាពជាដៃគូរវាងម្ចាស់ជំនួយ ប្រជាជន និងរដ្ឋាភិបាល<br>● ពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានច្បាប់ផ្សេងៗ<br>● អភិវឌ្ឍន៍ធនធានមនុស្សសំរាប់ការអភិវឌ្ឍន៍<br><u>ការផ្តល់ហិរញ្ញវត្ថុដល់មូលដ្ឋាន</u><br>● ពង្រឹងមូលដ្ឋានហិរញ្ញវត្ថុសំរាប់មូលដ្ឋាន<br><u>ការផ្តល់សិទ្ធិអំណាចដល់សហគមន៍</u><br>● ពង្រឹងសមត្ថភាពប្រជាជន |

វិធានការមួយចំនួននៅតាមយុទ្ធសាស្ត្រនីមួយៗដូចបានរៀបរាប់ខាងលើមានទំនាក់ទំនងគ្នា សំរាប់ក្រុងសៀមរាប/អង្គរឆ្នាំ២០២០ ។ ឌីយ៉ាក្រាមលំហូរអំពីការអភិវឌ្ឍន៍តាមលំដាប់នៃផែនការមេមានបង្ហាញនៅក្នុងរូបខាងក្រោម ។




រូបទី ២៧ : ឌីយ៉ាក្រាមលំហូរអំពីការអភិវឌ្ឍន៍

## ៥.២ ផែនការអភិវឌ្ឍន៍តាមវិស័យ

ផ្នែកនេះរាយការណ៍សង្ខេបអំពីខ្លឹមសារនៃផែនការអភិវឌ្ឍន៍តាមវិស័យនីមួយៗ។ ការរៀបរាប់លំអិតអំពីផែនការអភិវឌ្ឍន៍តាមវិស័យនេះមានលើកឡើងនៅក្នុងភាគទី៣នៃរបាយការណ៍នេះ។

### ១. ការអភិវឌ្ឍន៍ក្រុង

**បញ្ហា**

១. ការពង្រីកក្រុងគ្មានសណ្ដាប់ធ្នាប់

២. គុណភាពទាបនៃបរិស្ថាន កន្លែងទាក់ទាញ និងសោភ័ណភាពក្នុងមណ្ឌលក្រុង

៣. កំរិតទាបនៃអនាម័យ និងបរិស្ថានរស់នៅក្នុងតំបន់លំនៅដ្ឋាន

៤. បញ្ហាតាមតំបន់

៤.១ តំបន់ក្រុង

- អភិរក្សស្ថាបត្យកម្មសម័យអាណានិគមបារាំង
- ការធ្វើឱ្យក្រុងមានការទាក់ទាញដល់ភ្ញៀវទេសចរ
- ក្រុងដែលមានស្ទឹងល្អ និងពណ៌បៃតង
- ការលើកកំពស់តំបន់តាំងទីលំនៅដែលមានដង់ស៊ីតេខ្ពស់

៤.២ តំបន់សំរាប់ពង្រីកក្រុង

- ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមានកំរិត
- ការសាងសង់សណ្ឋាគារគ្មានសណ្ដាប់ធ្នាប់




**ប្រភព : ក្រុមសិក្សា JICA**

**រូបទី ២៨ : ចំណាត់ថ្នាក់តំបន់**

<table>
<tr><td>គោលដៅ</td><td>ធ្វើឱ្យទៅជាក្រុងដែលមានការទាក់ទាញ :<br>• <u>តំបន់ក្រុងសៀមរាប</u> : ធ្វើឱ្យក្រុងសៀមរាបក្លាយជាតំបន់ដែលមានការទាក់ទាញបំផុតនៅអាស៊ីអាគ្នេយ៍ ។<br>• <u>តំបន់ជនបទ / បេតិកភណ្ឌ</u> : សហគមន៍ជនបទរស់នៅដោយសុខមង្គលជាមួយនឹងបេតិកភណ្ឌ ដែលមានការទ្រទ្រង់ដល់វិស័យទេសចរណ៍ និងការអភិរក្ស ។<br>• <u>តំបន់ទន្លេសាប</u> : តំបន់ទេសចរណ៍ធម្មជាតិ ដែលមានការការពារ និងប្រើប្រាស់បរិស្ថានធម្មជាតិចំរុះប្រកបដោយនិរន្តរភាព ។</td></tr>
<tr><td>យុទ្ធសាស្ត្រ</td><td><u>តំបន់ក្រុង</u><br>១. បង្កើតក្រុងទំនើបដោយមានការអនុវត្តន៍ផែនការក្រុងប្រកបដោយប្រសិទ្ធភាពខ្ពស់<br>២. អភិវឌ្ឍឡើងវិញតំបន់ផ្សារចាស់ និងធ្វើសមាហរណកម្មតំបន់នេះ<br>៣. អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងផ្លូវក្នុងក្រុង<br><u>ក្របខ័ណ្ឌស្ថាប័ន</u><br>៤. បង្កើតគណៈកម្មការខេត្តសំរាប់ការគ្រប់គ្រងដី ការធ្វើផែនការក្រុង និងសំណង់<br>៥. ការកសាងសមត្ថភាពសំរាប់ការរៀបចំ និងពង្រីងក្រុង<br>៦. ការផ្តល់មូលនិធិសំរាប់ការធ្វើផែនការក្រុង</td></tr>
<tr><td>គំរោង/ កម្មវិធី</td><td>U-1 គំរោងលើកកំពស់តំបន់ផ្សារចាស់<br><br><br>រូបទី ២៩ : ផែនការរួមសំរាប់គំរោងកែលំអតំបន់ផ្សារចាស់</td></tr>
</table>



ប្រភព : ក្រុមសិក្សា JICA

រូបគំនូរ ១ : ទិដ្ឋភាពឧទ្យានក្នុងក្រុង



ប្រភព : ក្រុមសិក្សា JICA

រូបគំនូរ ២ : ទិដ្ឋភាពផ្សារ



ប្រភព : ក្រុមសិក្សា JICA

រូបគំនូរ ៣ : ទិដ្ឋភាពតំបន់ផ្សារចាស់



ប្រភព : ក្រុមសិក្សា JICA

រូបគំនូរ : ទិដ្ឋភាពវិថីស៊ីសុវត្ថា

U-2 ការកសាងសមត្ថភាពក្នុងការធ្វើផែនការក្រុង




រូបទី ៣០ : ពង្រាងផែនការប្រើប្រាស់ដី

U-3 បញ្ជីសារពើភ័ណ្ឌនៃស្ថាបត្យកម្មប្រវត្តិសាស្ត្រដែលមានតំលៃសំរាប់អភិរក្សក្នុងក្រុងសៀមរាប

U-4 ការលើកកំពស់ការអភិវឌ្ឍន៍លំនៅដ្ឋាន

U-5 ការធ្វើផែនការ និងការអនុវត្តន៍សណ្ឋាគារ តំបន់វប្បធម៌ និងទេសចរណ៍សំរាប់ច្រកចូលថ្មីទៅកាន់អង្គរ

<table>
<tr><th colspan="2">២. ការគ្រប់គ្រងបរិស្ថាន</th></tr>
<tr><td>បញ្ហា</td><td>
១. យន្តការ និងសមត្ថភាពស្ថាប័នសំរាប់គ្រប់គ្រងបរិស្ថានមិនអាចដោះស្រាបបញ្ហាបរិស្ថាន ដែលបណ្តាលមកពីការពង្រីកក្រុង និងការអភិវឌ្ឍន៍យ៉ាងលឿន ។<br>
២. ពុំមានគំនិតយល់ដឹងខាងបរិស្ថានគ្រប់គ្រាន់សំរាប់ធ្វើផែនការ<br>
៣. អាកប្បកិរិយារបស់ប្រជាជន និងជំនួញពុំមានការគាំទ្រដល់បរិស្ថាន<br>
៤. វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈសំរាប់ការអភិរក្សបរិស្ថានមិនអាចទប់ទល់នឹងវិនិយោគខាងជំនួញយ៉ាងឆាប់រហ័ស ។<br>
<br>
រូបថត ៥.១ : អណ្តូងស្អុយ បង្គន់ និងការចោលសំរាមដែលនៅជិតផ្ទះ<br>
<br>
រូបថត ៥.២ : លូពេញដោយសំរាម<br>
<br>
រូបថត: ៥.៣ លូពេញដោយសំណល់រាវ
</td></tr>
<tr><td>គោលដៅ</td><td>
ធ្វើការគ្រប់គ្រងបរិស្ថានសមស្របដើម្បីធ្វើឱ្យសៀមរាបកាន់តែមានសោភ័ណភាពឡើង និងបរិស្ថានកាន់តែមាននិរន្តរភាព :<br>
• ធ្វើឱ្យទីក្រុងសៀមរាបកាន់តែស្រស់ស្អាតឡើងសមស្របទៅនឹងលក្ខណៈខ្មែរ និងបេតិកភណ្ឌអង្គរ ដោយយកចិត្តទុកដាក់ខ្ពស់ទៅលើមជ្ឈមណ្ឌលក្រុង និងរមណីយដ្ឋានអង្គរ និង<br>
• ធ្វើក្រុងមានការសន្សំសំចៃធនធានទឹកដើម្បីកាត់បន្ថយបន្ទុកបរិស្ថានមកនូវត្រឹម ១០%
</td></tr>
<tr><td>យុទ្ធសាស្ត្រ</td><td>
១. ពង្រឹងសមត្ថភាពស្ថាប័នលើការគ្រប់គ្រងបរិស្ថានដើម្បីដោះស្រាយបញ្ហាដែលបណ្តាលមកពីការអភិវឌ្ឍន៍យ៉ាងលឿន<br>
២. ផែនការអភិវឌ្ឍន៍ដែលគិតគូរពីបញ្ហាបរិស្ថាន<br>
៣. ជំរុញឱ្យមានការកែប្រែអាកប្បកិរិយាមនុស្សឱ្យចេះស្រលាញ់បរិស្ថាន<br>
៤. បង្កើតប្រព័ន្ធហិរញ្ញវត្ថុសំរាប់ការអភិរក្សបរិស្ថាន (មើលរូបទី៣២)
</td></tr>
</table>

| គំរោង / កម្មវិធី | E-1 ពង្រឹងសមត្ថភាពស្ថាប័ន<br>E-2 លើកកំពស់ការយល់ដឹងបរិស្ថាន<br>E-3 ប្រមូលតំលៃសេវាកម្មជាមួយគ្នានឹងសេវាកម្មសាធារណៈផ្សេងៗទៀត |
|---|---|




ប្រភព : ក្រុមសិក្សា JICA

**រូបទី ៣១ : គោលដៅ យុទ្ធសាស្ត្រវិធី និងលំដាប់កម្មវិធី**




ប្រភព: ផ្អែកលើ 'Wada, Gomi planning, 2005', modified by JICA Study Team.

រូបទី ៣២ : យុទ្ធសាស្ត្រ និងការគ្រប់គ្រងបរិស្ថាននៅពេលបច្ចុប្បន្ន និងអនាគត

## ៣. ការអភិវឌ្ឍន៍វិស័យទេសចរណ៍

| | |
|---|---|
| បញ្ហា | ១. ទេសចរណ៍នៅសៀមរាបត្រូវចាត់ទុកជាទេសចរណ៍ប្រមូលផ្តុំ ស្នាក់នៅរយៈពេលខ្លី បើពិនិត្យលើពេលវេលា និងកន្លែងដើរកំសាន្ត។ នោះគឺជាប្រភេទទេសចរណ៍ប្រមូលផ្តុំផ្ចាក់កណ្តាលដែលមក ទស្សនានៅកន្លែងមួយចំនួនក្នុងរដូវមានភ្ញៀវច្រើន ស្នាក់នៅរយៈពេលខ្លី ។ ប្រភេទភ្ញៀវទេសចរគឺជា ភ្ញៀវទេសចរជាក្រុមមានភ្ញៀវទេសចរដើរកំសាន្តគ្មានផែនការច្បាស់លាស់ភាគច្រើនក្នុងចំណោមភ្ញៀវបុគ្គល និងមានចំនួនភ្ញៀវទេសចរតិចតួចនៅរដូវវស្សា<br>២. កំណើនទេសចរណ៍បែបប្រមូលផ្តុំនេះធ្វើឱ្យបរិស្ថានធ្លាក់ចុះ និងគំរាមកំហែងដល់និរន្តរភាពទេសចរណ៍ ប៉ុន្តែផ្តល់ផលប្រយោជន៍សេដ្ឋកិច្ចតិចតួចដល់ប្រជាជននៅជនបទ ។<br>៣. ក្រុងសៀមរាប/អង្គរពុំទាន់ត្រៀមខ្លួនរួចរាល់ក្នុងការទាក់ទាញប្រភេទភ្ញៀវទេសចរផ្សេងៗ ដែលស្នាក់នៅក្នុង |

| | |
|---|---|
| | ក្រុងរយៈពេលយូរ ។ ចំណុចខ្សោយទាក់ទងនឹងកន្លែងកំសាន្តមានដូចខាងក្រោម :<br>▪ កន្លែងកំសាន្តរបស់ភ្ញៀវទេសចរមួយចំនួនមិនបានអភិវឌ្ឍន៍ឱ្យបានសមរម្យ ពោលគឺតំបន់កំសាន្តទាំងនោះពុំមានហេដ្ឋារចនាសម្ព័ន្ធល្អ : លំបាកក្នុងការធ្វើដំណើរទៅកាន់ធនធានទេសចរណ៍នៅ តំបន់ឆ្ងាយៗ ។<br>▪ មិនអាចផ្តល់ភ្ញៀវទេសចរនូវបទពិសោធន៍ផ្ទាល់ជាមួយនឹងវប្បធម៌ ប្រវត្តិសាស្ត្រ សិល្បៈ និងរបៀបរស់នៅតាមបែបប្រពៃណី<br>▪ កង្វះខាតសេវាកម្ម និងបដិសណ្ឋារកិច្ច<br>▪ ពុំមានសន្តិសុខ និងភាពងាយស្រួលគ្រប់គ្រាន់សំរាប់ភ្ញៀវទេសចរបុគ្គលម្នាក់ៗដើរកំសាន្តនៅជុំវិញក្រុង<br>៤. ទីផ្សារទេសចរណ៍អន្តរជាតិទទួលស្គាល់ក្រុងសៀមរាប/អង្គរជាកន្លែងទេសចរណ៍មានការទាក់ទាញដោយសារប្រាសាទអង្គរវត្ត ប៉ុន្តែពុំមានសុវត្ថិភាពគ្រប់គ្រាន់សំរាប់ឱ្យភ្ញៀវទេសចរបុគ្គលម្នាក់ៗដើរ កំសាន្តជុំវិញក្រុងបាន ។<br>៥. ទីផ្សារ និងការលើកកំពស់ទេសចរណ៍រវាងដៃគូរវាងរដ្ឋ-ឯកជននៅមានកំរិតខ្សោយ ។<br>▪ កង្វះខាតធនធានមនុស្សសំរាប់ការលើកកំពស់ទេសចរណ៍<br>▪ កង្វះខាតបទពិសោធន៍ក្នុងការលើកកំពស់ទេសចរណ៍ |
| គោលដៅ | បង្កើតតំបន់ទេសចរណ៍គុណភាពដោយផ្អែកលើបេតិកភណ្ឌអង្គរ<br>*- សំរាប់ធ្វើឱ្យភ្ញៀវទេសចរទទួលបានបទពិសោធន៍ផ្ទាល់ទៅនឹងវប្បធម៌ ប្រវត្តិសាស្ត្រ សិល្បៈ និងរបៀបរស់នៅរបស់ខ្មែរ ដែលមានលក្ខណៈស្របគ្នាទៅនឹងធម្មជាតិសម្បូរបែប ។* |
| យុទ្ធសាស្ត្រ | ១. អភិវឌ្ឍតំបន់ទេសចរណ៍ និងផ្លូវទស្សនាកំសាន្តសម្បូរបែប<br>▪ រមណីយដ្ឋានបេតិកភណ្ឌអង្គរ<br>▪ តំបន់ទេសភាពក្រុង និងតំបន់ទេសចរណ៍វប្បធម៌<br>▪ បឹងទន្លេសាប និងតំបនជនបទ<br>▪ តំបន់រមណីដ្ឋានអង្គរឆ្ងាយៗ<br>២. ផ្តល់ឱ្យភ្ញៀវទេសចរនូវរសជាតិវប្បធម៌ ប្រវត្តិសាស្ត្រ សិល្បៈ និងធម្មជាតិរបស់ខ្មែរដ៏សម្បូរបែប<br>៣. កែលំអសេវាកម្ម និងបដិសណ្ឋារកិច្ចសំរាប់ឱ្យការស្នាក់នៅរបស់ភ្ញៀវមានភាពសប្បាយរីករាយ<br>៤. ពង្រឹងទីផ្សារទេសចរណ៍ និងលើកកំពស់ទេសចរណ៍តាមរយៈភាពជាដៃគូរវាងរដ្ឋ-ឯកជន ដោយតំរង់ទិសភ្ញៀវទេសចរដែលមានកំរិតចំណាយខ្ពស់ ។ |
| គំរោង/<br>កម្មវិធី | TO-1 គំរោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ និងបណ្តាញទេសចរណ៍បេតិកភណ្ឌអង្គរ<br>TO-2 គំរោងអភិវឌ្ឍន៍ទីផ្សារសំរាប់កំសាន្តពេលយប់<br>TO-3 កម្មវិធីលើកកំពស់ទេសចរណ៍គុណភាពតាមរយៈភាពជាដៃគូរវាងរដ្ឋ-ឯកជន<br>TO-4 ការអភិវឌ្ឍន៍ និងការលើកកំពស់ទេសចរណ៍តាមភូមិ និងទេសចរណ៍ធម្មជាតិ<br>TO-5 ពង្រឹងបណ្តាញនាំភ្ញៀវ និងការបង្កើតប្រព័ន្ធនាំភ្ញៀវទំនើប<br>TO-6 សិក្សាលំអិតលើលទ្ធភាពទទួលភ្ញៀវទេសចរ និងការគ្រប់គ្រងរមណីយដ្ឋាន ។ |




ប្រភព : ក្រុមសិក្សាJICA

រូបទី ៣៣ : តំបន់ និងបណ្ដាញរមណីយដ្ឋានអង្គរផ្សេងៗ

| ៤ . ការពង្រីកវិស័យកសិកម្ម និងផ្សព្វផ្សាយផលិតផលក្នុងស្រុក | |
|---|---|
| បញ្ហា | ១. មានលេចចេញសកម្មភាពជាក្រុមក្នុងចំណោមកសិករ ជាពិសេសជំនួញតាមសហគមន៍<br>២. ទំនាក់ទំនងរវាងផលិតផលក្នុងស្រុកជាមួយផ្នែកទេសចរណ៍នៅមានកំរិត : មានចំណែកតូចនៃផលិតផលក្នុងស្រុកក្នុងទីផ្សារទេសចរណ៍សៀមរាប<br>៣. ផលិតផលកសិកម្មដែលបានពង្រីកមានសក្ដានុពលក្នុងទីផ្សារក្នុងស្រុក និងទីផ្សារទេសចរណ៍ ផ្ទុយទៅវិញកសិករមួយចំនួនជួបប្រទះនឹងកង្វះខាតបទពិសោធន៍លើកសិ-ជំនួញថ្មីៗ ដូចជា បន្លែ សត្វ និងទីផ្សារកសិកម្ម ។<br>៤. ផលិតផលកែច្នៃដោយដៃនៅមូលដ្ឋាន និងវត្ថុអនុស្សាវរីយ៍មានសក្ដានុពលក្នុងទីផ្សារលក់ទំនិញក្នុងស្រុក និងទីផ្សារនាំចេញ<br>៥. សកម្មភាពគាំទ្រពីថ្នាក់ខេត្តមានកំរិត ដោយសារកង្វះខាតព័ត៌មាននៃឧស្សាហកម្មជនបទ ធនធានមនុស្សទន់ខ្សោយ និងកង្វះខាតបទពិសោធន៍<br>៦. បទពិសោធន៍ប្រកបដោយជោគជ័យនៃគំរោងសាកល្បង "ការតាំងពិព័រណ៍ផលិតផលអង្គរ ឆ្នាំ២០០៥" ឆ្លុះបញ្ចាំងពីសក្ដានុពលនៃទីផ្សារថ្នាក់កណ្ដាលនៅមូលដ្ឋានដែលកំពុងមានកំណើន និងផ្ដល់ទំនុកចិត្តដល់មន្ត្រីសមភាគី (មើលរូបទី៣៥) ។ |
| គោលដៅ | ការបង្កើតផ្លាកសញ្ញាពាណិជ្ជកម្មអង្គរ |
| យុទ្ធសាស្ត្រ | ១. បង្កើតប្រព័ន្ធគាំទ្រសំរាប់លើកកំពស់ផលិតផលកសិកម្ម និងផលិតផលក្នុងស្រុកផ្សេងៗទៀត<br>២. តំរង់ទិសដៅទៅរកទីផ្សារទេសចរណ៍ ព្រមទាំងទីផ្សារថ្នាក់កណ្ដាលដែលកំពុងមានកំណើន (មើលរូបទី៣៥) |

| | |
|---|---|
| | ៣. ពង្រឹងទំនាក់ទំនងរវាងវិស័យទេសចរណ៍ និងសេដ្ឋកិច្ចមូលដ្ឋាន<br>៤. ពង្រឹងហេដ្ឋារចនាសម្ព័ន្ធសំរាប់ពង្រីកកសិកម្ម និងផ្សព្វផ្សាយផលិតផលក្នុងស្រុក |
| គំរោង/កម្មវិធី | A-1 ការអភិវឌ្ឍន៍ធនធានមនុស្ស និងការបង្កើតមជ្ឈមណ្ឌលលើកផ្សព្វផ្សាយផលិតផលអង្គរ<br>A-2 ចលនាភូមិមួយ ផលិតផលមួយ<br>A-3 ការអភិវឌ្ឍន៍ភូមិផលិតកម្ម<br>A-4 ការតាំងពិព័រណ៍ផលិតផលអង្គរ |




រូបទី ៣៤ : គោលបំណង យុទ្ធសាស្ត្រ មជ្ឈមណ្ឌលផ្សព្វផ្សាយផលិតផលអង្គរ និងគំរោង/កម្មវិធីផ្សេងៗ

**អតីតកាល**

**ប្រភេទទីផ្សារពីរដោយឡែកពីគ្នា**

**(គ្មានប្រភេទផ្សារកំរិតកណ្ដាល)**

មានទីផ្សារពីរដាច់ដោយឡែកពីគ្នា។ ទីផ្សារមួយគឺសំរាប់ប្រជាជនដែលរកចំណូលបានទាប និងទីផ្សារមួយទៀតសំរាប់ភ្ញៀវទេសចរ បរទេស។



**បច្ចុប្បន្ន**

មានការកើតឡើងនូវទីផ្សារកសិកម្មកណ្តាល និងទីផ្សារទេសចរណ៍ដែលកំពុងមានកំណើន

មានការកើតឡើងនូវទីផ្សារកសិកម្មកណ្តាលនៅពេលមានកសិកម្មចំណូលកើនឡើង។ ទីផ្សារទេសចរណ៍ក៏មានកំណើនផងដែរ។




**អនាគត**

ទីផ្សារកសិកម្មកណ្តាល និងទីផ្សារទេសចរណ៍ដែលមានកំណើន

ជាចុងក្រោយ ទីផ្សារកសិកម្មកណ្តាលមានភាពលើសលប់។ ទីផ្សារទេសចរណ៍នឹងត្រូវបានដាក់បញ្ចូលដោយចាត់ទុកជាផ្នែកមួយនៃទីផ្សារដ៏សម្បូរបែបនៅមូលដ្ឋាន

ផលិតផល

ទីផ្សារ




**ប្រភព : ក្រុមសិក្សា JICA**

**រូបទី ៣៥ : ការវិវត្តន៍ផ្នែកទីផ្សារ (គោលគំនិតគំរូ)**

| **៥. ការដឹកជញ្ជូន** | |
|---|---|
| បញ្ហា | ១. បណ្តាញផ្លូវថ្នល់មិនគ្រប់គ្រាន់ និងចរាចរណ៍ចង្អៀតនៅតាមផ្លូវជាតិលេខ៦ នៅក្នុងតំបន់ក្រុង<br>២. ការត្រួតពិនិត្យចរាចរណ៍នៅតាមរមណីយដ្ឋានអង្គរ<br>៣. លទ្ធភាពកំណត់ក្នុងការធ្វើដំណើរទៅកាន់រមណីយដ្ឋានឆ្ងាយៗ<br>៤. កង្វះខាតផ្លូវដែលមានសុវត្ថិភាព និងសោភ័ណភាព<br>៥. ការយល់ដឹងពីសាធារណៈលើច្បាប់ចរាចរណ៍<br>៦. កង្វះខាតលើការថែទាំផ្លូវ |

<table>
<tr><td>គោលដៅ</td><td>
■ ផ្តល់បណ្តាញផ្លូវ និងមុខងារគ្រប់គ្រាន់សំរាប់ភាពងាយស្រួលនៃការធ្វើដំណើរ<br>
■ ធ្វើឱ្យភ្ញៀវទេសចរពេញចិត្តនឹងទស្សនាអង្គរ និងស្នាក់នៅសៀមរាប<br>
■ ឈានមុខក្នុងការពង្រីកក្រុង បន្ទាប់ពីធ្វើផែនការក្រុង
</td></tr>
<tr><td>យុទ្ធសាស្ត្រ</td><td>
១. កែលំអស្ថានភាពរាំងស្ទះ និងបង្កើតបណ្តាញផ្លូវរណបប្រទាក់ក្រឡាក្នុងតំបន់ក្រុង<br>
 <br>
ប្រភព : ក្រុមសិក្សា JICA     ប្រភព: ក្រុមសិក្សា JICA<br>
រូបទី ៣៦ : បណ្តាញផ្លូវសំខាន់ៗ<br>
ឆ្នាំ២០១២     ឆ្នាំ២០២០<br>
២. កែលំអស្ថានភាពផ្លូវ និងស្ពានក្នុងតំបន់ក្រុង<br>
៣. បង្កើតបណ្តាញផ្លូវសំរាប់តំបន់ពង្រីកក្រុងនៅពេលអនាគត<br>
៤. លើកកំពស់លទ្ធភាពធ្វើដំណើរទៅកាន់រមណីយដ្ឋានអង្គរផ្សេងៗ<br>
៥. បង្កើតប្រព័ន្ធថែទាំផ្លូវឱ្យមានប្រសិទ្ធភាព
</td></tr>
<tr><td>គំរោង/ កម្មវិធី</td><td>
TR-1 គំរោងកែលំអស្ពានពីសម័យបារាំង<br>
TR-2 គំរោងសាងសង់ផ្លូវរណបប្រទាក់ក្រឡាស្របនឹងផ្លូវជាតិលេខ ៦ ( ជំហាន ១)<br>
TR-3 កែលំអផ្លូវសន្តិភាពហ៊ុន សែន ( ជំហាន ២)<br>
 <br>
ប្រភព : ក្រុមសិក្សា JICA     ប្រភព: ក្រុមសិក្សា JICA<br>
រូបទី ៣៧ : ផ្លូវ TR- ២ (ជំហាន ១)     រូបទី ៣៨ : ផ្លូវ TR- ៣ (ជំហាន ២)<br>
TR-4 សាងសង់បញ្ចប់បណ្តាញផ្លូវរណបប្រទាក់ក្រឡាក្នុងតំបន់ក្រុងរហូតដល់ឆ្នាំ ២០១២ ( ជំហាន ៣)<br>
TR-5 សាងសង់បញ្ចប់បណ្តាញផ្លូវរណបប្រទាក់ក្រឡាក្នុងតំបន់ក្រុងរហូតដល់ឆ្នាំ ២០២០ ( ជំហាន ៤)
</td></tr>
</table>



ប្រភព : ក្រុមសិក្សា JICA

រូបទី ៣៩ : ផ្លូវ TR- ៤ (ជំហាន ៣)



ប្រភព: ក្រុមសិក្សា JICA

រូបទី ៤០ : ផ្លូវ TR- ៥ (ជំហាន ៤)

TR-6 ការលើកកំពស់ស្ថាប័ន និងយុទ្ធនាការសំរាប់សុវត្ថិភាពតាមផ្លូវថ្នល់

TR-7 គំរោងស្តារបណ្តាញផ្លូវទៅកាន់តំបន់បេតិកភណ្ឌឆ្ងាយៗ

TR-8 គំរោងចាប់ផ្តើមការដឹកជញ្ជូនសាធារណៈដែលមិនបំពុលបរិស្ថានក្នុងរមណីយដ្ឋានអង្គរ

TR-9 គំរោងសាងសង់ផ្លូវសំរាប់ជិះកង់ក្នុងរមណីយដ្ឋានអង្គរ

TR-10 ការលើកកំពស់ស្ថាប័នសំរាប់ថែទាំផ្លូវឱ្យមានប្រសិទ្ធភាព




ប្រភព : ក្រុមសិក្សា JICA

រូបទី ៤១ : បណ្តាញផ្លូវទៅកាន់រមណីយដ្ឋានឆ្ងាយៗ (TR-7)




ប្រភព : ក្រុមសិក្សា JICA

រូបទី ៤២ : ផ្លូវឡានក្រុងដែលបានស្នើឡើង និងតំបន់ហាមឃាត់ឡានឯកជន

| ៦. ធនធានទឹក និងការផ្គត់ផ្គង់ទឹក | |
|---|---|
| បញ្ហា | ១. កង្វះខាតការគ្រប់គ្រងធនធានទឹក : កង្វះខាតព័ត៌មានគ្រឹះសំរាប់ធ្វើផែនការ កង្វះខាតទិន្នន័យត្រួតពិនិត្យផែនការគ្រប់គ្រង និងអនុវត្ត និងក្របខ័ណ្ឌច្បាប់ ។<br>២. ការពឹងផ្អែកខ្លាំងលើការយកទឹកក្រោមដីក្នុងតំបន់កណ្តាលក្រុងអាចបណ្តាលឱ្យកំរិតទឹកក្រោមដីធ្លាក់ចុះ និងការបាក់ស្រុតដី<br>៣. កង្វះខាតសេវាកម្មផ្គត់ផ្គង់ទឹកសាធារណៈ ដែលឱ្យអត្រាគ្របដណ្តប់ផ្គត់ផ្គង់មានកំរិតទាប |
| គោលដៅ | ១. អភិវឌ្ឍធនធានទឹកសំរាប់ការផ្គត់ផ្គង់ទឹក កសិកម្ម និងបរិស្ថាន<br>២. លើកកំពស់សមត្ថភាព និងអត្រាគ្របដណ្តប់នៃសេវាកម្មផ្គត់ផ្គង់ទឹកសាធារណៈ<br>៣. គ្រប់គ្រង និងអភិរក្សទឹកក្រោមដី |
| យុទ្ធសាស្ត្រ | <u>**យុទ្ធសាស្ត្រសំរាប់ធនធានទឹក**</u><br>១. អភិវឌ្ឍធនធានទឹកប្រកបដោយនិរន្តរភាព<br>២. ផែនការអភិវឌ្ឍន៍ធនធានទឹកប្រកបដោយនិរន្តរភាព<br>៣. លើកកំពស់អនាម័យនៅតាមស្ទឹង និងបរិស្ថានទឹកនៃរមណីយដ្ឋានអង្គរ<br><u>**យុទ្ធសាស្ត្រសំរាប់ការផ្គត់ផ្គង់ទឹក**</u><br>៤. ផ្គត់ផ្គង់ទឹកឱ្យបានគ្រប់គ្រាន់សំរាប់ប្រជាជន និងជំនួញ<br>៥. គ្រប់គ្រងការផ្គត់ផ្គង់ទឹកឱ្យមានប្រសិទ្ធភាពដើម្បីកាត់បន្ថយគំលាតរវាងរយៈពេលតំរូវការទាប និងរយៈពេលតំរូវការខ្ពស់<br>៦. លើកកំពស់សេវាកម្មផ្គត់ផ្គង់ទឹកដើម្បីពង្រីកអត្រាគ្របដណ្តប់តាមរយៈការខិតខំប្រឹងប្រែងបំពេញចិត្តអតិថិជន ។ |

គំរោង/ កម្មវិធី

**<u>ផែនការអភិវឌ្ឍន៍ធនធានទឹក</u>**

- ទឹកក្រោមដីនៃបឹងទន្លេសាបសំរាប់ការផ្គត់ផ្គង់ទឹក
- ទឹកបារាយណ៍ខាងលិចសំរាប់ធារាសាស្ត្រ និងការបង្ហូរតាមស្ទឹងសំរាប់បរិស្ថាន
- បារាយណ៍ភាគឦសានសំរាប់ធារាសាស្ត្រ




ប្រភព : ក្រុមសិក្សា JICA

រូបទី ៤៣ : ការកំណត់ដំបូងលើការប្រើប្រាស់ធនធានទឹក

**<u>ផែនការអភិវឌ្ឍន៍ការផ្គត់ផ្គង់ទឹក</u>**




រូបទី ៤៤ : កម្មវិធីពេលវេលា និងសមត្ថភាពនៃការអភិវឌ្ឍន៍តាមដំណាក់

**<u>គំរោង/កម្មវិធីដែលបានស្នើឡើង</u>**

W-1 ការកំណត់នៅថ្នាក់ខេត្តលើការចុះបញ្ជីនៃអណ្តូងពាណិជ្ជកម្ម

W-2 អនុក្រឹត្យស្តីពីទឹកក្រោមដី

W-3 ការជំនួសបំពង់ទឹកចាស់ៗ

W-4 សិក្សាផែនយុទ្ធសាស្ត្រអំពីការគ្រប់គ្រងធនធានទឹករួមគ្នាសំរាប់អាងស្ទឹងសៀមរាប និងអាងស្ទឹងរលួស

W-5 អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកក្នុងក្រុងសៀមរាប (ដំណាក់កាលទី ១)

W-6 អភិវឌ្ឍធនធានទឹកនៅបារាយណ៍ភាគឦសាន

W-7 អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកនៅក្រុងសៀមរាប (ដំណាក់កាលទី ២)



ប្រភព : ក្រុមសិក្សា JICA

រូបទី ៤៥ : លំដាប់នៃគំរោង/កម្មវិធី

## ៣ .ការគ្រប់គ្រងសំណល់រឹង

**បញ្ហា**

១. សំណល់រឹងត្រូវបានពង្រាយនៅទីសាធារណៈដែលបង្កផលប៉ះពាល់អវិជ្ជមានមួយចំនួនដូចជា :

- ធ្វើឱ្យខូចខាតដល់បរិស្ថាន ដូចជា ការបំពុលទឹកក្រោមដី ស្ទះផ្លូវទឹក សត្វចង្រៃច្រើន និងក្លិនស្អុយ
- ប៉ះពាល់សោភ័ណភាព និងហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងបង្កផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរដល់ភ្ញៀវទេសចរ
- បញ្ហាសង្គមផ្សេងៗ ដូចជាកំណើនមនុស្សរើសសំរាមក្នុងក្រុង និង
- អាចបង្កផលប៉ះពាល់អវិជ្ជមានធ្ងន់ធ្ងរលើបរិស្ថាននៅតាមតំបន់ជុំវិញកន្លែងចោលសំរាម នៅពេលអនាគត។

២. សំរាមពង្រាយដោយសារ :

- កង្វះខាតការយល់ដឹងពីបញ្ហាសំរាមរបស់ប្រជាជន និងកែប្រែជីវិតរស់នៅទៅជាជីវិត "ចោល សំរាម"
- អាជ្ញាធរទទួលខុសត្រូវពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងសំណល់រឹង
- អត្រានៃការប្រមូលសំណល់លំនៅដ្ឋាននៅមានកំរិតទាបដោយសារតំលៃនៃការប្រមូលសំរាមខ្ពស់
- មានការពឹងផ្អែកហួសហេតុលើផ្នែកឯកជនក្នុងការគ្រប់គ្រងសំរាម
- ប្រព័ន្ធហិរញ្ញវត្ថុទន់ខ្សោយសំរាប់ការគ្រប់គ្រងសំរាម

**គោលដៅ**

**គោលដៅ**

ការធ្វើឱ្យក្រុងមាន "សោភ័ណភាព" សំរាប់ជនគ្រប់រូប

- តំបន់ក្រុងសៀមរាប : ការធ្វើឱ្យក្រុងមានសោភ័ណភាព
- តំបន់រមណីយដ្ឋានអង្គរ : គំរូនៃការគ្រប់គ្រងបរិស្ថានក្នុងប្រទេសកម្ពុជា

**ចំណុចគោលដៅនៃការគ្រប់គ្រងសំណល់រឹង**

- ការគ្របដណ្តប់នៃការប្រមូលសំណល់ : ១០០ %នៅតាមលំនៅដ្ឋានក្នុងក្រុង និងកន្លែងជំនួញ
- ប្រព័ន្ធចោលសំរាមចុងក្រោយ : កន្លែងចោលសំរាមអនាម័យ
- ចំនួននៃការចោលសំរាម : តិចជា ៦០០ ក្រាមរបស់មនុស្សម្នាក់ក្នុង ១ ថ្ងៃសំរាប់សំណល់លំនៅ ដ្ឋាន និងតិចជាង ១,២០០ ក្រាមសំរាប់មនុស្សម្នាក់ក្នុងមួយថ្ងៃសំរាប់សំណល់ទាំងអស់
- គោលដៅនៃការកែច្នៃឡើងវិញ : សំណល់មិនមែនសរីរាង្គចំនួនតិចជាង ២០% ត្រូវធ្វើការកែច្នៃឡើងវិញ ដោយប្រើវិធានការយកចិត្តទុកដាក់បរិស្ថានទាំងបី ( កាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ) ។
- តំលៃនៃការគ្រប់គ្រងសំណល់រឹង : ៣០ ដុល្លារក្នុងមួយតោន ។




ប្រភព : ក្រុមសិក្សា JICA

**រូបទី ៤៦ : ចំនួនសំណល់ និងវិធានការកាត់បន្ថយ ប្រើប្រាស់ឡើងវិញ និងកែច្នៃឡើងវិញ**

**យុទ្ធសាស្ត្រ**

១. ពង្រឹងការយល់ដឹងរបស់ប្រជាជនលើបញ្ហាបរិស្ថាន

- ពីចំណុចគោលដៅទៅកាន់ចំណុចផ្សេងៗទៀត
- យកចិត្តទុកដាក់ទៅលើក្រុមអាយុផ្សេងៗដោយប្រើប្រាស់វិធីសាស្ត្រខុសៗគ្នា
- ប្រើប្រាស់ដើមទុនសង្គម




ប្រភព : ក្រុមសិក្សា JICA

រូបទី ៤៧ : យុទ្ធសាស្ត្រសំរាប់ពង្រីកក្រុមគោលដៅ

២. បង្កើតប្រព័ន្ធគ្រប់គ្រងសំណល់ដែលមានបច្ចេកទេសខ្ពស់ដោយការបង្កើតឱ្យមានស្ថាប័នទទួលខុសត្រូវនៅក្នុងអាជ្ញាធរខេត្ត និងអភិវឌ្ឍន៍សមត្ថភាពរបស់ពួកគេសំរាប់ធ្វើផែនការ និងការគ្រប់គ្រង ។

៣. បង្កើតប្រព័ន្ធហិរញ្ញវត្ថុសមស្របមួយសំរាប់ការគ្រប់គ្រងសំណល់រឹងដោយការភ្ជាប់ទៅពន្ធ ឬដោយការភ្ជាប់កំរៃជាមួយនឹងកំរៃនៃការប្រើប្រាស់ផ្សេងៗទៀត ។

៤. ពង្រឹងភាពជាដៃគូរវាងរដ្ឋ-ឯកជន

- វិស័យសាធារណៈ :ការងារធ្វើផែនការ សំរបសំរួល និងត្រួតពិនិត្យ ការលំបាកផ្សេងៗទៀតសំរាប់វិស័យឯលជន
- វិស័យឯកជន : ការងារគ្រប់គ្រងសំណល់

គំរោង/កម្មវិធី

**<u>គោលគំនិតនៃប្រព័ន្ធគ្រប់គ្រងសំណល់រឹង</u>**

គោលគនិតនៃប្រព័ន្ធគ្រប់គ្រងសំណលរឹងដែលបានស្នើឡើង : កាត់បន្ថយចំនួនសំណល់ដល់កំរិតអប្បបរមា




ប្រភព : ក្រុមសិក្សា JICA

រូបទី ៤៨ : គោលគំនិតនៃប្រព័ន្ធគ្រប់គ្រងសំណល់រឹងដែលបានស្នើឡើង

## ផែនការសំរាប់ស្ថាប័ន

ប្រព័ន្ធរដ្ឋបាល :

- មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត : ការអនុវត្តន៍ការគ្រប់គ្រងសំណល់រឹង និងការត្រួតពិនិត្យលើអ្នកធ្វើកិច្ចសន្យា
- មន្ទីរបរិស្ថានខេត្ត : ត្រួតពិនិត្យលក្ខខណ្ឌបរិស្ថានផ្សេងៗប្រព័ន្ធអនុវត្ត

| | ប្រភពហិរញ្ញវត្ថុ | ការប្រមូលសំណល់ | ការចោលសំណល់ |
|---|---|---|---|
| សំរេលល់នៅដ្ឋាន | អាជ្ញាធរខេត្តទទួលខុសត្រូវប្រភពហិរញ្ញវត្ថុ (រួមានជំរើសនៃការធ្វើកិច្ចសន្យាប្រមូលសំរាម) | ធ្វើកិច្ចសន្យាទៅឱ្យក្រុមហ៊ុនឯកជន | អាជ្ញាធរខេត្តទទួលខុសត្រូវ និងធ្វើកិច្ចសន្យាទៅឱ្យក្រុមហ៊ុនដើម្បីអនុវត្តការងារ |
| សំរេលល់ក្រៅពីលំនៅដ្ឋាន | ក្រុមហ៊ុនឯកជនទទួលខុសត្រូវប្រភពហិរញ្ញវត្ថុ | ក្រុមហ៊ុនឯកជន | ដូចខាងលើ |
| សំណល់តាមកន្លែងសាធារណៈ (ផ្លូវ ឧទ្យាន ស្ទឹង ។ល។ | អាជ្ញាធរខេត្តទទួលខុសត្រូវប្រភពហិរញ្ញវត្ថុ | ធ្វើកិច្ចសន្យាជាមួយនឹងក្រុមហ៊ុនឯកជន | ដូចខាងលើ |

## គំរោង/កម្មវិធីដែលបានស្នើឡើង

SW-1 ការអភិវឌ្ឍន៍ប្រព័ន្ធគ្រប់គ្រងសំណល់រឹង

SW-2 ការពង្រឹងប្រព័ន្ធប្រមូលសំណល់

SW-3 ការអភិវឌ្ឍន៍កន្លែងចាក់សំរាមអនាម័យ

(សូមអានកម្មវិធីពាក់ព័ន្ធ E-2 ការលើកកំពស់ចំណេះដឹងបរិស្ថានក្នុងចំណោមប្រជាជន និងស្ថាប័នជំនួញ ) ។

## ៨. ប្រព័ន្ធបង្ហូរទឹក និងប្រព័ន្ធបង្ហូរសំណល់រាវ

**បញ្ហា**

១. មានការលិចទឹកជាញឹកញាប់នៅតាមមណ្ឌលពាណិជ្ជកម្ម និងតំបន់ស្នាក់នៅរបស់ភ្ញៀវទេសចរ ដោយសារ :

- លូធំហរពុំមានសមត្ថភាពគ្រប់គ្រាន់សំរាប់បង្ហូរទឹកភ្លៀង និង
- លូធំហរស្ទះដោយសារសំរាម

២. ការលិចទឹកបណ្តាលឱ្យមានបញ្ហាសុខភាព/អនាម័យដូចខាងក្រោម :

- ធ្វើឱ្យលិចផ្ទះ និងទ្រព្យសម្បត្តិដោយសារទឹកភ្លៀង និងសំណល់រាវនៅពេលភ្លៀងខ្លាំង
- សំណល់ពីអាងប្រព្រឹត្តិកម្មទឹកហូរផ្ទាល់ទៅលូបណ្តាលឱ្យមានក្លាក់ងារនាំជំងឺ និង
- បញ្ហាសុខភាព និងសោភ័ណ្ឌភាពដែលបណ្តាលមកពីកង្វះអនាម័យក្នុងតំបន់ដែលមានដង់ស៊ីតេ ខ្ពស់ និងតំបន់ដែលមានករីតចំណូលទាប

<table>
<tr>
<td></td>
<td>


<br>ប្រភព : ក្រុមសិក្សា JICA
<br>រូបទី ៤៩ : ប្រព័ន្ធបង្ហូរទឹកបច្ចុប្បន្ន
<br>
<br>រូបថត ៥.៤ : ការលិចទឹកនៅតាមបណ្ដោយផ្លូវជាតិស៊ីវុត្ថា (ខែកញ្ញា ឆ្នាំ ២០០៥)
<br>៣. ផលប៉ះពាល់អវិជ្ជមាននៃទឹកជំនន់ទៅលើបរិស្ថានមាន :
<br>▪ បង្កើតកករបំពុលក្នុងស្ទឹងសៀមរាប លូបង្ហូរទឹក និងប្រឡាយធារាសាស្ត្រ និង
<br>▪ ប្រឡាយតូចៗ និងប្រភពទឹកក្រោមដីរងការបំពុលកាន់តែច្រើនឡើងដោយសំណល់រាវ និងការជ្រាបចូលទៅក្នុងដីនៃទឹកភ្លៀង
</td>
</tr>
<tr>
<td>គោលដៅ</td>
<td>
បង្កើតប្រពន្ធ័បង្ហូរទឹក និងសំណល់រាវ ប្រកបដោយនិរន្តរភាព សំរាប់អនាម័យ និងសោភ័ណភាពក្រុង :
<br>១. លើកកំពស់សុខភាព និងអនាម័យ
<br>២. លើកកំពស់សុខភាព និងអនាម័យក្រុងនៅតាមតំបន់ជុំវិញ
<br>៣. ទប់ស្កាត់ការបំផ្លាញបរិស្ថាន និងលើកកំពស់គុណភាពទឹកក្នុងស្ទឹងសៀមរាប
</td>
</tr>
</table>

| | |
|---|---|
| យុទ្ធសាស្ត្រ | ១. បង្កើតឱ្យមានការគ្រប់គ្រងសំណល់រួម ដូចជា៖<br>២. ការគ្រប់គ្រងទឹកភ្លៀង និង<br>• ការស្តារសមត្ថភាពនៃលូបច្ចុប្បន្ន<br>• ផ្តល់សមត្ថភាពប្រព័ន្ធបង្ហូរទឹកបន្ថែម<br>• ធ្វើប្រព្រឹត្តិកម្មទឹកភ្លៀងក្នុងក្រុងរួចនាំទៅកាន់អាងស្តុកទឹក<br>• បង្វែរទឹកភ្លៀងពីតំបន់កណ្តាលក្រុងចេញពីស្ទឹងសៀមរាប<br>• បង្កើតកន្លែងស្តុកនៅភាគខាងលើស្ទឹងដើម្បីកាត់បន្ថយផលប៉ះពាល់នៃកំលាំងហូរនៅតាមតំបន់ ក្រោមស្ទឹង<br>៣. ការគ្រប់គ្រងសំណល់រាវ<br>• បែងចែកប្រព័ន្ធប្រមូលសំណល់រាវដែលឆ្លងកាត់តំបន់ក្រុងដោយការដាក់ប្រព័ន្ធពីកំរិតមធ្យមទៅកំរិតខ្ពស់នៃដង់ស៊ីតេប្រជាជន ការផ្តល់សេវាកម្មទឹក និងការយកចិត្តទុកដាក់លើតំបន់ សណ្ឋាគារ / ផ្ទះសំណាក់ ។ |
| គំរោង/<br>កម្មវិធី | ដំណាក់កាលផ្សេងៗសំរាប់គោលបំណង និងការធ្វើអន្តរាគមន៍<br><br><br>**ប្រភព៖ ក្រុមសិក្សា** JICA<br>**រូបទី ៥០ ៖ គោលបំណង/ ដំណាក់កាលអន្តរាគមន៍**<br>១. ដំណាក់ ១៖ ការលើកកំពស់សុខភាព និងអនាម័យដោយការកែលំអប្រព័ន្ធបង្ហូរទឹក ពោលគឺនាំទឹកចេញពីកន្លែងផ្ទុកសំណល់រាវពីកន្លែងតាំងទីលំនៅ និងកាត់បន្ថយឧប្បត្តិហេតុជំនន់ ។<br>២. ដំណាក់ ២៖ លើកកំពស់បរិស្ថានកន្លែងរស់នៅក្នុងតំបន់ក្រុងដែលមានដង់ស៊ីតេទាប ( តំបន់ ២ និង តំបន់ ៣) ដោយការតម្លើង និងថែរក្សាអាងប្រព្រឹត្តិកម្មសមស្របនៅតាមលំនៅដ្ឋាន និងសណ្ឋាគារ/ ផ្ទះសំណាក់ ។<br>៤. ដំណាក់ ៣៖ ការពារគុណភាពទឹក និងការពារការធ្លាក់ចុះបរិស្ថានដោយការអនុវត្តប្រព័ន្ធកណ្តាលក្នុងតំបន់១ រួចពង្រីកទៅកាន់តំបន់ ២ ។ |

ផែនការលើកកំពស់ប្រព័ន្ធបង្ហូរទឹក




ប្រភព ៖ ក្រុមសិក្សា JICA

រូបទី ៥១ ៖ ការលើកកំពស់ប្រព័ន្ធបង្ហូរទឹកដែលបានស្នើឡើង ៖ ផ្នែកខាងលិច

តារាង ១២ ៖ ការលើកកំពស់ប្រព័ន្ធបង្ហូរទឹកដែលបានស្នើឡើង – ភាគខាងលិច

| កន្លែងផ្ទុកទឹក | ការកែលំអដែលស្នើឡើង |
|---|---|
| ខាងលើស្ទឹង ផ្លូវជាតិល.៦<br><br>VI | • បង្កើតកន្លែងស្តុកទឹកភ្លៀងដើម្បីសម្រួលដល់ការហូរខ្លាំង និងការពារតំបន់ខាងក្រោមស្ទឹង<br>• បង្កើតលូទឹកក្រោមដីដើម្បីបញ្ចេញទឹកភ្លៀងនៅតាមវិថីសម្តេចទេពវង្សដើម្បីបង្វែរទឹកចេញពីប្រព័ន្ធទឹកកណ្តាលក្រុង។ |
| VII | • ផ្តល់នូវប្រព័ន្ធលូថ្មីនៅភាគខាងលិចដើម្បី បង្កើនសមត្ថភាពស្តុកទឹកភ្លៀងនិងផ្តល់ច្រក ចេញសំរាប់កន្លែងផ្ទុកទឹកទី VI។ |
| VIII | • ផ្តល់នូវកន្លែងស្តុកទឹកដើម្បីកាត់បន្ថយការការហូរនៅពេលមានទឹកខ្លាំង និងគ្រប់គ្រងល្បឿនហូរ<br>• បង្វែរទឹកពីប្រឡាយ មុននឹងទៅដល់ផ្លូវវង់ខាងក្រៅ<br>• បង្វែរទឹកដែលមានចំនួនច្រើនជ្រុលពីបំពង់ទឹកនៅតាមផ្លូវវង់ទៅដាក់អាងស្តុកទឹក |
| | |

| | |
|---|---|
| នៅផ្លូវជាតិលេខ ៦ | • ផ្តល់នូវទ្វារទឹកធំ១នៅទីតាំងបីដើម្បីបញ្ចេញទឹកជំនន់ទៅតាមដងផ្លូវភាគខាងជើង ។<br>• ផ្តល់នូវទ្វារទឹកតូចៗដែលមានចំងាយពីមួយទៅមួយចំនួន ២៥០ ម៉ែត្រ<br>• ជីកស្រះសំរាប់ស្តុកទឹកនៅតាមផ្លូវជាតិលេខ ៦ ដែលមានទំហំ ៥០ ម៉ែត្រ ។ |
| នៅខាងក្រោមស្ទឹង | • បង្កើតរចនាសម្ព័ន្ធគ្រប់គ្រងទឹកភ្លៀងដើម្បីបង្វែរការហូរពីច្រកហូរចេញពីបំពង់ទឹកភាគខាងលិច<br>• បង្វែរប្រឡាយបាកសាស្ត្រ C4 ទៅកាន់កន្លែងផ្ទុកទី IX ។ |

## ផែនការគ្រប់គ្រងសំណល់រាវ

### តារាង ១៣ : សំណើរៀបចំការធ្វើសេវាកម្ម

| | 2012 | 2020 |
|---|---|---|
| តំបន់ ១ | កណ្តាល | កណ្តាល |
| តំបន់ ២ | តាមកន្លែងដាក់ស្តែង | កណ្តាល |
| តំបន់ ៣ | តាមកន្លែងដាក់ស្តែង | តាមកន្លែងដាក់ស្តែង |
| តំបន់អប្សរា | តាមកន្លែងដាក់ស្តែង ឬតាមផ្ទែក | តាមកន្លែងដាក់ស្តែង ឬតាមផ្ទែក |




ប្រភព : ក្រុមសិក្សា JICA

រូបទី ៥២ : ការគ្រប់គ្រងសំណល់រាវដែលបានស្នើឡើង



ប្រភព : ក្រុមសិក្សា JICA

រូបទី ៥៣ : សំណើប្លង់នៃប្រព័ន្ធសំណល់រាវ




**រូបទី ៥៤ : លំដាប់នៃការអនុវត្តន៍គំរោង**

SD-1 គំរោងអភិវឌ្ឍន៍ទេសចរណ៍ទន្លេមេគង្គ ភាគ A1 : ការលើកកំពស់ប្រព័ន្ធបង្ហូរទឹក និងសំណល់រាវក្នុងតំបន់មួយស្ថិតនៅភាគខាងលិចស្រុក។

SD-2 គំរោងអភិវឌ្ឍន៍ក្រុងសៀមរាប-អង្គរ : ប្រព័ន្ធបង្ហូរទឹកក្នុងភាគខាងកើតស្រុក

SD-3 គំរោងប្រព័ន្ធបង្ហូរសំណល់រាវនៅសៀមរាប - ដំណាក់១ : ប្រព័ន្ធបង្ហូរទឹក និងសំណល់តំបន់មួយស្ថិតនៅភាគ

| | |
|---|---|
| | ខាងលិចស្រុក<br>SD-4 គំរោងប្រព័ន្ធបង្ហូរសំណល់រាវនៅសៀមរាប - ជំហាន២ : ប្រព័ន្ធបង្ហូរសំណល់នៅតំបន់មួយ ស្ថិតនៅភាគខាងកើតស្រុក<br>SD-5 គំរោងបញ្ចេញទឹកភ្លៀងមណ្ឌលក្រុងសៀមរាប : ប្រព័ន្ធបង្ហូរសំណល់រាវនៅភាគខាងលិចស្រុក<br>SD-6 គំរោងគ្រប់គ្រងទឹកស្អុយនៅសៀមរាប ជំហាន១ : ការចោលសំណល់កកពីសំណល់រាវនៅខាងលិចស្រុក<br>SD-7 គំរោងគ្រប់គ្រងទឹកស្អុយនៅសៀមរាប ជំហាន ២ : ការចោលសំណល់កកពីសំណល់រាវ នៅខាងកើតស្រុក<br>SD-8 កគំរោងបញ្ចេញចោលទឹកបន្ទាប់ពីឆ្លងកាត់ប្រព្រឹត្តិកម្មក្នុងអាងប្រព្រឹត្តិកម្ម ជំហាន១ : ការបញ្ចេញចោលសំណល់រាវក្រោយពីឆ្លងកាត់ប្រព្រឹត្តិកម្មក្នុងអាងប្រព្រឹត្តិកម្មនៅតំបន់ ២ ភាគខាលិចស្រុក ។<br>SD-9 កគំរោងបញ្ចេញចោលទឹកបន្ទាប់ពីឆ្លងកាត់ប្រព្រឹត្តិកម្មក្នុងអាងប្រព្រឹត្តិកម្ម ជំហាន ១I : ការបញ្ចេញចោលសំណល់រាវក្រោយពីឆ្លងកាត់ប្រព្រឹត្តិកម្មក្នុងអាងប្រព្រឹត្តិកម្មនៅតំបន់២ ភាគខាងកើតស្រុក ។ |

| ៩. ថាមពល | |
|---|---|
| បញ្ហា | ១. ការលំបាកក្នុងការផ្គត់ផ្គង់ថាមពលឱ្យបានគ្រប់គ្រាន់ និងជឿទុកចិត្តបានរបស់អ្នកប្រើប្រាស់ ដោយសារ :<br>▪ កង្វះខាតសមត្ថភាពគ្រប់គ្រង<br>▪ ប្រព័ន្ធថាមពលប្រើម៉ាស៊ូតមួយប្រភេទគត់ ដែលជាកត្តាប្រឈមនឹងការដាច់ចរន្ត<br>២. តំបន់គ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនីនៅមានកំណត់ដោយសារតែបណ្តាញចែកចាយតូច<br>៣. ប្រពន្ធ័ចែកចាយការផ្គត់ផ្គង់មានតែមួយ<br>៤. អត្រាពន្ធអគ្គិសនីខ្ពស់<br>៥. សមត្ថភាពថែទាំនៅមានកំរិត |
| គោលដៅ | ផ្គត់ផ្គង់ថាមពលអគ្គិសនីដែលគួរឱ្យទុកចិត្តសំរាប់ទាំងអស់គ្នាដែលប៉ះពាល់តិចតួចដល់បរិស្ថាន<br>• ពង្រីកបណ្តាញអគ្គិសនីនៅតំបន់ក្រុង និងតំបន់ជុំវិញក្រុងត្រឹមឆ្នាំ២០១២<br>• ធ្វើឱ្យមានអគ្គិសនី ១០០% នៅក្នុងស្រុកសៀមរាបទាំងមូលត្រឹមឆ្នាំ២០២០ |
| យុទ្ធសាស្ត្រ | ១. បង្កើន និងពង្រីករចនាសម្ព័ន្ធថាមពល<br>១.១ អភិវឌ្ឍប្រភពថាមពលបន្ថែម<br>១.២ ពង្រីក និងកែលំអបណ្តាលថាមពល<br>២. ពង្រឹង EdC<br>២.១ ពិនិត្យអត្រាពន្ធឡើងវិញ និងតំលៃភ្ជាប់អគ្គិសនី<br>២.២ ពង្រឹង EdC<br>៣. អនុវត្តច្បាប់ បទបញ្ជា និងក្រឹត្យច្បាប់ដើម្បីកាត់បន្ថយបន្ទុកបរិស្ថាន |

<table>
<tr>
<td></td>
<td>


ប្រភព : ក្រុមសិក្សា JICA<br>
រូបទី ៥៥ : សេណារីយ៉ូរួមសំរាប់វិស័យអគ្គីសនី
</td>
</tr>
<tr>
<td>គំរោង/<br>កម្មវិធី</td>
<td>
PO-1 ការបំពាក់ជាបន្ទាន់នូវម៉ាស៊ីនប្រើម៉ាស៊ូត<br>
PO-2 គំរោងពង្រីកស្ថានីយ៍ថាមពលប្រើ ម៉ាស៊ូតនៅពេលបច្ចុប្បន្ន<br>
PO-3 គំរោងសំរាប់ពង្រីកនៃបណ្តាញបែងចែកអគ្គីសនី<br>
PO-4 គំរោងសំរាប់តម្លើង និងជុសជុលភ្លើងតាមវិថីនានា<br>
PO-5 ការធ្វើផែនការនៃការប្រើប្រាស់អគ្គីសនីប្រកបដោយប្រសិទ្ធភាពខ្ពស់សំរាប់ប្រាសាទអង្គរវត្ត និងប្រាសាទផ្សេងៗ<br>
PO-6 ការធ្វើផែនការសំរាប់បំភ្លឺតំបន់ដែលពុំទាន់មានភ្លើង<br>
PO-7 ជំនួយដល់ការកសាងសមត្ថភាព EdC<br>
PO-8 ជំនួយលើការពិនិត្យឡើងវិញនូវអត្រាពន្ធភ្លើង<br>
PO-9 គំរោងសំរាប់ពិនិត្យ ឬបង្កើតច្បាប់ បទបញ្ជា និងក្រឹត្យច្បាប់អំពីការផ្គត់ផ្គង់អគ្គីសនីដើម្បីកាត់ បន្ថយបន្ទុកបរិស្ថាន<br>
PO-10 គំរោងដើម្បីរកប្រភពថាមពលប្រកបដោយនិរន្តរភាពសំរាប់ស្រុកសៀមរាប ។
</td>
</tr>
</table>




ប្រភព : ក្រុមសិក្សា JICA

រូបទី ៥៦ : ការប៉ាន់ស្មានពីតម្រូវការ និងការផ្គត់ផ្គង់អគ្គិសនី




ប្រភព : ក្រុមសិក្សា JICA

រូបទី ៥៧ : ផែនការបែងចែកអគ្គិសនីឆ្នាំ ២០០៤




ប្រភព: ក្រុមសិក្សា JICA

រូបទី ៥៨ : ផែនការបែងចែកអគ្គិសនីឆ្នាំ ២០១២




ប្រភព៖ ក្រុមសិក្សា JICA

រូបទី ៥៩ : ផែនការបែងចែកអគ្គីសនីឆ្នាំ ២០២០




រូបទី ៦០ : លំដាប់នៃការអភិវឌ្ឍន៍រហូតដល់ឆ្នាំ ២០២០

# ៦. គំរោង និងកម្មវិធី

## ៦.១ បញ្ជីនៃគំរោង និងកម្មវិធីនានា

ជំពូកនេះធ្វើការពិពណ៌នាសង្ខេបអំពីគំរោង និងកម្មវិធីដែលបានស្នើឡើងសំរាប់វិស័យពាក់ព័ន្ធ។ ការពិពណ៌នាលំអិតមាន បង្ហាញនៅក្នុងភាគទី ៣ នៃរបាយការណ៍នេះ។

**តារាង ១៤: បញ្ជីគំរោង និងកម្មវិធី (១/២)**

| លេខ | គោលការណ៍ ពាក់ព័ន្ធ | វិស័យ | លេខ កូដ | ឈ្មោះគំរោង/កម្មវិធី | ការពិពណ៌នាសង្ខេប | ស្ថាប័ន/ទីភ្នាក់ងារអនុវត្ត | អាទិភាព | តំលៃ ១០០០$ | ឆ្នាំអនុវត្ត 2006 | 2012 | 2020 |
|---|---|---|---|---|---|---|---|---|---|---|---|
| 1 | 3,4,5 | ក្រុង | U-1 | ការកែលំអតំបន់មណ្ឌលក្រុង | ហេដ្ឋារចនាសម្ព័ន្ធ និងទេសភាពចាំបាច់ផ្សេងៗ | ខេត្ត មន្ទីរពាក់ព័ន្ធ | អាទិភាព | 7,600 | | | |
| 2 | 3,5,6 | | U-2 | កសាងសមត្ថភាពធ្វើផែនការក្រុង | អភិវឌ្ឍសមត្ថភាពសំរាប់ចក្រវិស័យ និងផែនការប្រើប្រាស់ដី ធ្វើផែនការក្រុង និងផែនការប្រើប្រាស់ដី | ដែនដី ស្រុក អប្សរា ខេត្ត | អាទិភាព | 500 | | | |
| 3 | 3 | | U-3 | ការចុះបញ្ជីស្ថាបត្យកម្មប្រវត្តិសាស្ត្រ | បញ្ជីសារពើភ័ណ្ឌស្ថាបត្យកម្មពីសម័យបារាំង | អប្សរា/ខេត្ត | | 200 | | | |
| 4 | 3,5 | | U-4 | លើកកំពស់ការអ.វ.តំបន់លំនៅដ្ឋាន | ផ្តល់បរិយាកាសរស់នៅល្អសំរាប់ចំណុចថ្មី | អប្សរា ស្រុក ឯកជន | | n/a | | | |
| 5 | 1,3,4 5 | | U-5 | អភិវឌ្ឍតំបន់វប្បធម៌ និងទេសចរណ៍ | អ.វ.តំបន់សំរាប់ការ ១/ខ និងសណ្ឋាគារប្រណិត | អប្សរា វិនិយោគិនឯកជន | | n/a | | | |
| 6 | 4,6 | បរិស្ថាន | E-1 | អភិវឌ្ឍសមត្ថភាពស្ថាប័ន | លើកកំពស់សមត្ថភាពស្ថាប័នសំរាប់វិស័យសាធារណៈ | ខេត្ត សាធារណការ ម.បរិស្ថាន ប្រជាជន | | 310 | | | |
| 7 | 3,4 | | E-2 | លើកកំពស់ការយល់ដឹងបរិស្ថាន | បណ្តុះបណ្តាលបរិស្ថាន ជាពិសេស ចំពោះសិស្សសាលា | សាលាបឋមសិក្សា | អាទិភាព | 330 | | | |
| 8 | 4,5,6 | | E-3 | ប្រមូលកំរៃពីសេវាកម្មសាធារណៈ | ប្រមូលថ្លៃឈ្នួលសំរាប់ប្រើទឹក សំណល់រាវ និងសំណល់រឹង | [illegible] | | 310 | | | |
| 9 | 1,2,3, 5,6 | ទេសចរណ៍ | TO-1 | បណ្តាញទេសចរណ៍បេតិកភណ្ឌខ្មែរ និងការអភិវឌ្ឍន៍ | លើកកំពស់កន្លែងទេសចរណ៍ថ្មីនៅជុំវិញសៀមរាប | ក្រ. និងម.ទេសចរណ៍ អប្សរា សាធារណការ ក្រ.វប្បធម៌ | អាទិភាព | 26,550 | | | |
| 10 | 2,3 | | TO-2 | អភិវឌ្ឍផ្សារពេលយប់ | បង្កើតការទាក់ទាញ និងជំរើសសំរាប់កំសាន្តពេលយប់ | ផ្នែកឯកជន | | 260 | | | |
| 11 | 1,2,3 | | TO-3 | លើកកំពស់គុណភាពទេសចរណ៍តាមរយៈរដ្ឋ-ឯកជន | ភាពជាដៃគូរដ្ឋ-ឯកជនសំរាប់ទីផ្សារ និងការផ្សព្វផ្សាយ | នឹងកំណត់នៅពេលក្រោយ | អាទិភាព | n/a | | | |
| 12 | 1,2,6 | | TO-4 | អភិវឌ្ឍ និងលើកកំពស់ទេសចរណ៍ធម្មជាតិ និងភូមិ | អង្កេតតាមភូមិ អង្កេតសំរាប់គំរោងសាកល្បង និងជ្រើសរើសផលិតផលសំរាប់ទេសចរ | អង្គការមិនមែនរដ្ឋាភិបាល អប្សរា | | 158 | | | |
| 13 | 1,2 | | TO-5 | បណ្តុះបណ្តាលជំនាញនាំភ្ញៀវ និងប្រព័ន្ធនាំភ្ញៀវទំនើប | ជ្រើសរើសកម្មវិធីបណ្តុះបណ្តាលនាំភ្ញៀវ និងលើកកំពស់ប្រព័ន្ធផ្តល់លិខិតអនុញ្ញាត | ក្រ. និងមន្ទីរទេសចរណ៍ អប្សរា | | 211 | | | |
| 14 | 1,5 | | TO-6 | សិក្សាពីសមត្ថភាពទទួលភ្ញៀវតាមទីកន្លែង និងការគ្រប់គ្រង | សិក្សា/វិភាគពីចំនួនភ្ញៀវ សមត្ថភាពទីកន្លែង និងការគ្រប់គ្រងទីកន្លែង | អប្សរា | | 163 | | | |
| 15 | 1,2,6 | ពាណិជ្ជកម្ម, និងក.ផលិតកម្ម | A-1 | ការអភិវឌ្ឍធនធានមនុស្ស និងមជ្ឈ. មណ្ឌលផ្សព្វផ្សាយផលិតផល | អភិវឌ្ឍសមត្ថភាពខេត្ត និងបង្កើតមជ្ឈមណ្ឌល ផ្សព្វផ្សាយផលិតផលក្នុងស្រុក | ខេត្ត APPC | អាទិភាព | 80 | | | |
| 16 | 1,2,6 | | A-2 | ចលនាភូមិមួយផលិតផលមួយ | លើកកំពស់ចលនាភូមិមួយ ផលិតផលមួយ | ខេត្ត APPC | | 60 | | | |
| 17 | 1,2,6 | | A-3 | អភិវឌ្ឍភូមិផលិតកម្ម | សកម្មភាពប្រមូលផ្តុំរបស់អ្នកភូមិ និងការទំនាក់ទំនងជាមួយទេសចរណ៍ | ខេត្ត APPC | | 36 | | | |
| 18 | 1,2,3 | | A-4 | ការតាំងពិព័រណ៍ផលិតផលអង្ករ | រៀបចំការតាំងពិព័រណ៍ផលិតផលអង្ករ ស្រូវពូជល្អទៅនឹងគំរោងសាកល្បង | APPC | | 108 | | | |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 19 | 3,5 | មធ្យោបាយដឹកជញ្ជូន | TR-1 | កែលំអស្ពានសល់ពីសម័យបារាំង | សាងសង់ស្ពានបន្ថែមឆ្លងស្ទឹងសៀមរាប | មន្ទីរសាធារណការ | អាទិភាព | 957 |
| 20 | 3,5 | | TR-2 | បណ្ដាញផ្លូវរយៈ ជំហាន ១ | អភិវឌ្ឍផ្លូវបីនៅក្នុងតំបន់ក្រុង | សាធារណការ និងខេត្ត | អាទិភាព | 10,839 |
| 21 | 3,5 | | TR-3 | បណ្ដាញផ្លូវរយៈ ជំហាន ២ | សាងសង់បញ្ចប់ផ្លូវហ៊ុន សែន | មន្ទីរសាធារណការ | | 6,617 |
| 22 | 3,5 | | TR-4 | បណ្ដាញផ្លូវរយៈ ជំហាន ៣ | បង្កើតផ្លូវជុំខាងក្នុង | សាធារណការ និងខេត្ត | | 16,736 |
| 23 | 3,5 | | TR-5 | បណ្ដាញផ្លូវរយៈ ជំហាន ៤ | អភិវឌ្ឍផ្លូវថ្មីៗក្នុងតំបន់ពាក់កណ្ដាលទីប្រជុំជនបច្ចុប្បន្ន | ខេត្ត | | 14,921 |
| 24 | 3,6 | | TR-6 | អភិវឌ្ឍផ្លូវថ្មីៗ នៅតាមតំបន់ពាក់កណ្ដាលក្រុងបច្ចុប្បន្ន | ពង្រឹងច្បាប់ចរាចរណ៍ផ្អែកការផ្ដល់សិទ្ធិបើកបរ សុវត្ថិភាព និងការពាក់មួកការពារ | ប៉ូលិស សាធារណការ និងខេត្ត | | 7,000 |
| 25 | 2,3,5 | | TR-7 | ស្ពានបណ្ដាញផ្លូវទៅតាមតំបន់ទេសចរណ៍នៅជនបទ | កែលំអផ្លូវទៅកាន់រមណីយដ្ឋានប្រាសាទឆ្ងាយៗ | សាធារណការ និង អភិវឌ្ឍន៍ជនបទ | អាទិភាព | 33,160 |
| 26 | 3,4,5 | | TR-8 | មធ្យោបាយដឹកជញ្ជូនសាធារណៈដែលមិនបំពុលបរិស្ថាន | ប្រព័ន្ធឡានក្រុងដែលមានការបំពុលតិចទៅកាន់រមណីយដ្ឋានប្រាសាទបុរាណ | អប្សរា | | 7,104 |
| 27 | 3,4,5 | | TR-9 | សាងសង់ផ្លូវសំរាប់ជិះកង់ | បង្កើតផ្លូវសំរាប់កង់នៅតាមរមណីយដ្ឋានប្រាសាទបុរាណ | អប្សរា | | 1,417 |
| 28 | 3,5,6 | | TR-10 | លើកកំពស់សមត្ថភាពស្ថាប័នសំរាប់ថែទាំផ្លូវ | រៀបចំបញ្ជីផ្លូវ និងបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានផ្លូវ | សាធារណការ និង អភិវឌ្ឍន៍ជនបទ | | 1,800 |

## តារាង ១៥ : បញ្ជីគំរោង និងកម្មវិធី (២/២)

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| 29 | 4,5,6 | ទឹក | W-1 | ការត្រួតពិនិត្យរបស់ខេត្តលើការ និងការបំពាក់នាឡិកាទឹក | ការបង្កើនការប្រើប្រាស់សំរាប់ពាណិជ្ជកម្ម និងការតម្លើងទឹកម៉ាស៊ីន | ខេត្ត | | 0 |
| 30 | 5,6 | | W-2 | អនុក្រឹត្យថ្នាក់ក្រសួងស្ដីពីការយកការប្រើប្រាស់ទឹកក្រោមដី | បង្កើតអនុក្រឹត្យស្ដីពីការប្រើប្រាស់ទឹកក្រោមដី | ខេត្ត | | 0 |
| 31 | 4,5 | | W-3 | ប្ដូរបំពង់ទឹកចាស់ | ប្ដូរបំពង់ទឹកចាស់ (៦.៥ គីឡូម៉ែត្រ) ក្នុងតំបន់កណ្ដាលក្រុង | មន្ទីរឧស្សាហកម្ម ថាមពល រ៉ែ | អាទិភាព | 450 |
| 32 | 4,5 | | W-4 | សហប្រតិបត្តិការអន្តរក្រសួងសំរាប់ការគ្រប់គ្រងធនធានទឹក | រៀបចំការគ្រប់គ្រងធនធានទឹកតាមបែបសមាហរណកម្ម | ក្រសួងធនធានទឹក | អាទិភាព | 7.282 |
| 33 | 4,5 | | W-5 | អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកនៅសៀមរាប ជំហាន ១ | បង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកថ្មី | មន្ទីរឧស្សាហកម្ម ថាមពល រ៉ែ | | 13.716 |
| 34 | 4,5 | | W-6 | អភិវឌ្ឍធនធានទឹកនៅបារាយណ៍ភាគឦសាន | លើកកំពស់ទុនបំរុងបារាយណ៍ភាគឦសានឱ្យទៅជាធនធានទឹក | ក្រសួងធនធានទឹក | | 8.320 |
| 35 | 4,5 | | W-7 | អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកនៅសៀមរាប ជំហាន ២ | បង្កើតរោងចក្រប្រព្រឹត្តិកម្មទឹក និងប្រព័ន្ធបែងចែកទឹក | មន្ទីរឧស្សាហកម្ម ថាមពល រ៉ែ | | 12,310 |
| 36 | 3,4,5 6 | សំណល់រឹង | SW-1 | អភិវឌ្ឍប្រព័ន្ធ/គ្រប់គ្រងសំណល់រឹងសមរម្យ | អភិវឌ្ឍប្រព័ន្ធហិរញ្ញវត្ថុ និងស្ថាប័នសំរាប់គ្រប់គ្រងសំណល់រឹង | ក្រុមហ៊ុនសហប្រតិបត្តិការ-វិនិយោគយ៉ុង និងខេត្ត | | 1.000 |
| 37 | 3,4,5 6 | | SW-2 | ពង្រីកប្រព័ន្ធប្រមូលសំណល់ | ពង្រីកការប្រមូលសំណល់រឹងឱ្យបាន ១០០ % | ក្រុមហ៊ុនសហប្រតិបត្តិការ-វិនិយោគយ៉ុង និងខេត្ត | | 300 |
| 38 | 4,5,6 | | SW-3 | កន្លែងចាក់សំរាមអនាម័យ | លើកកំពស់ការអនុវត្តន៍នៅតាមកន្លែងចាក់សំរាមបច្ចុប្បន្ន និងផែនការសំរាប់កន្លែងថ្មី | ក្រុមហ៊ុនសហប្រតិបត្តិការ-វិនិយោគយ៉ុង និងខេត្ត | | 2.000 |
| 39 | 3,4,5 | ប្រព័ន្ធលូទឹក និងសំណល់រាវ | SD-1 | គំរោងអភិវឌ្ឍន៍ទេសចរណ៍មេគង្គ ក១ | លើកកំពស់ប្រព័ន្ធលូទឹកក្នុងក្រុង | សាធារណការ (ជំនួយADB) | | 11.988 |
| 40 | 3,4,5 | | SD-2 | គំរោងអភិវឌ្ឍន៍ក្រុងសៀមរាប | តម្លើងប្រព័ន្ធលូទឹក និងសំណល់រាវក្នុងតំបន់មណ្ឌលក្រុង | ខេត្ត និង សាធារណការ (ជំនួយ AFD) | អាទិភាព | 4.600 |
| 41 | 3,4,5 | | SD-3 | ប្រព័ន្ធលូសំណល់រាវ ជំហាន ១ | ប្រព័ន្ធប្រមូលសំណល់រាវក្នុងមណ្ឌលក្រុងភាគខាងលិច (តំបន់១) | ម. និងក្រសួងសាធារណការ | | 18.326 |
| 42 | 3,4,5 | | SD-4 | ប្រព័ន្ធលូសំណល់រាវ ជំហាន ២ | ប្រព័ន្ធប្រមូលសំណល់រាវក្នុងមណ្ឌលក្រុងភាគខាងកើត និងរោងចក្រប្រព្រឹត្តិកម្មថ្មី | ម. និងក្រសួងសាធារណការ | | 17.271 |
| 43 | 3,4,5 | | SD-5 | ការបង្ហូរទឹកភ្លៀង | ប្រព័ន្ធលូទឹកក្នុងក្រុងថ្មីនៅភាគខាងលិច | ម. និងក្រសួងសាធារណការ | | 10.935 |
| 44 | 3,4,5 | | SD-6 | ការគ្រប់គ្រងសំណល់រាវ (ជំហាន ១) | ចំរោះប្រព័ន្ធប្រមូលសំណល់រាវ និងរោងប្រព្រឹត្តិកម្មសំរាប់ (SD-1) | ម. និងក្រសួងសាធារណការ | | 1.614 |
| 45 | 3,4,5 | | SD-7 | ការគ្រប់គ្រងសំណល់រាវ (ជំហាន ២) | ចំរោះប្រព័ន្ធប្រមូលសំណល់រាវ និងរោងប្រព្រឹត្តិកម្មសំរាប់ (SD-4) | ម. និងក្រសួងសាធារណការ | | 1.027 |
| 46 | 3,4,5 | | SD-8 | ការបោះបង់សំណល់ បន្ទាប់ពីប្រព្រឹត្តិកម្ម ជំហាន ១ | ស្ដារប្រព័ន្ធដឹកជញ្ជូនប្រមូល និងនាំទឹកបន្ទាប់ពីប្រព្រឹត្តិកម្មទៅកាន់អាងចំរោះ ដោយ SD-3 | ម. និងក្រសួងសាធារណការ | | 13.137 |
| 47 | 3,4,5 | | SD-9 | ការបោះបង់សំណល់ បន្ទាប់ពីប្រព្រឹត្តិកម្ម ជំហាន ២ | ស្ដារប្រព័ន្ធដឹកជញ្ជូនប្រមូល និងនាំទឹកបន្ទាប់ពីប្រព្រឹត្តិកម្មទៅកាន់អាងចំរោះ ដោយ SD-3 | ម. និងក្រសួងសាធារណការ | | 7.634 |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 48 | 5,6 | ថាមពល | P-1 | ការបំពាក់ម៉ាស៊ីនភ្លើងម៉ាស៊ូតជាបន្ទាន់ | បំពាក់ម៉ាស៊ីនប្រើម៉ាស៊ូតថ្មី កំលាំង៨មេហ្គាវ៉ាត់ នៅទីតាំងអគ្គិសនីកម្ពុជា | អគ្គិសនីកម្ពុជា | អាទិភាព | 2.090 | | |
| 49 | 5 | | P-2 | ពង្រីកស្ថានីយ៍ថាមពលប្រើម៉ាស៊ីនបច្ចុប្បន្ន | ពង្រីកស្ថានីយ៍ថាមពលប្រើម៉ាស៊ូតឱ្យដល់កំរិត ១០ មេហ្គាវ៉ាត់ | អគ្គិសនីកម្ពុជា | | 20.800 | | |
| 50 | 5 | | P-3 | ពង្រីក និងបន្ថែមបណ្តាញចែកចាយ | បន្ថែមខ្សែដែលមានស្រាប់ និងខ្ពស់ និងបន្ថែមអនុស្ថានីយ៍ និងនាឡិកាវ៉ាត់ម៉ោងថ្មីៗ | អគ្គិសនីកម្ពុជា | | 7.800 | | |
| 51 | 3,5 | | P-4 | បំពាក់ និងជួសជុលភ្លើងតាមផ្លូវ | កែលម្អភ្លើងតាមផ្លូវសំរាប់ចរាចរ | ស្រុក | | 780 | | |
| 52 | 1,3,6 | | P-5 | ប្រើប្រាស់អគ្គិសនីប្រកបដោយប្រសិទ្ធភាពខ្ពស់សំរាប់អង្គរ និងប្រាសាទផ្សេងៗ | បំភ្លឺមណីយដ្ឋានអង្គរដោយប្រភពភ្លើងសាធារណៈ | អប្សរា / ស្ថាប័នពាក់ព័ន្ធ | | 330 | | |
| 53 | 2,5 | | P-6 | ធ្វើផែនការផ្គត់ផ្គង់អគ្គិសនីដល់កន្លែងដែលគ្មានអគ្គិសនី | ពង្រីកតំបន់មានអគ្គិសនី នៅពេលមានការពង្រីកក្រុង | អគ្គិសនីកម្ពុជា | | 275 | | |
| 54 | 5,6 | | P-7 | ជំនួយដល់ការកសាងសមត្ថភាពសំរាប់អគ្គិសនីកម្ពុជា | បណ្តុះបណ្តាលវិស្វករអគ្គិសនីកម្ពុជានៅសៀមរាប | អគ្គិសនីកម្ពុជា | | 550 | | |
| 55 | 5,6 | | P-8 | ជំនួយដល់ការពិនិត្យឡើងវិញនូវអត្រាតំលៃភ្លើង | ផ្តល់អត្រាតំលៃភ្លើងទៅតាមប្រភេទអ្នកប្រើប្រាស់ | អគ្គិសនីកម្ពុជា/ អាជ្ញាធរអគ្គិសនីកម្ពុជា | | 990 | | |
| 56 | 5,6 | | P-9 | ពិនិត្យឡើងវិញនូវច្បាប់ បទបញ្ជា និងក្រឹត្យទាក់ទងអគ្គិសនីដើម្បីបន្ថយបន្ទុកបរិស្ថាន | ពិនិត្យ កែសំរួល និងបង្កើតច្បាប់ពាក់ព័ន្ធដើម្បីកាត់បន្ថយបន្ទុកបរិស្ថាន | ក្រុង អគ្គិសនីកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា | | 1.800 | | |
| 57 | 5,6 | | P-10 | អភិវឌ្ឍប្រភពថាមពលចីរភាព | ស្វែងរកវិធីសំរាប់ប្រភពថាមពល | អគ្គិសនីកម្ពុជា ថាមពល | | 660 | | |
| 29 | 4,5,6 | ទឹក | W-1 | ការត្រួតពិនិត្យរបស់ខេត្តលើការ និងការបំពាក់នាឡិកាទឹក | ការចុះបញ្ជីអ្នកប្រើប្រាស់សំរាប់ពាណិជ្ជកម្ម និងការតម្លើងទឹកម៉ាស៊ីន | ខេត្ត | | 0 | | |
| 30 | 5,6 | | W-2 | អនុក្រឹត្យថ្នាក់ក្រសួងស្តីពីការយកកន្លែងប្រើប្រាស់ទឹកក្រោមដី | បង្កើតអនុក្រឹត្យស្តីពីការប្រើប្រាស់ទឹកក្រោមដី | ខេត្ត | | 0 | | |
| 31 | 4,5 | | W-3 | ប្តូរបំពង់ទឹកចាស់ | ប្តូរបំពង់ទឹកចាស់ (៦.៥ គីឡូម៉ែត្រ) ក្នុងតំបន់កណ្តាលក្រុង | មន្ទីរឧស្សាហកម្ម ថាមពល រ៉ែ | អាទិភាព | 450 | | |
| 32 | 4,5 | | W-4 | សិក្សាជាយុទ្ធសាស្ត្រស្តីពីសមាហរណកម្មនៃការគ្រប់គ្រងធនធានទឹក | រៀបចំការគ្រប់គ្រងធនធានទឹកតាមបែបសមាហរណកម្ម | ក្រសួងធនធានទឹក | អាទិភាព | 7.282 | | |
| 33 | 4,5 | | W-5 | អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកនៅសៀមរាប ដំណាក់កាល ១ | បង្កើតប្រព័ន្ធផ្គត់ផ្គង់ទឹកថ្មី | មន្ទីរឧស្សាហកម្ម ថាមពល រ៉ែ | | 13.716 | | |
| 34 | 4,5 | | W-6 | អភិវឌ្ឍធនធានទឹកនៅបារាយណ៍ភាគឦសាន | លើកកំពស់មុខងារបារាយណ៍ភាគឦសានឱ្យទៅជាធនធានទឹក | ក្រសួងធនធានទឹក | | 8.320 | | |
| 35 | 4,5 | | W-7 | អភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកនៅសៀមរាប ដំណាក់កាល ២ | បង្កើតរោងចក្រប្រព្រឹត្តិកម្មទឹក និងប្រព័ន្ធបែងចែកទឹក | មន្ទីរឧស្សាហកម្ម ថាមពល រ៉ែ | | 12.310 | | |
| 36 | 3,4,5 6 | សំណល់រឹង | SW-1 | អភិវឌ្ឍប្រព័ន្ធ/គ្រប់គ្រងសំរាមសមស្រប | អភិវឌ្ឍប្រព័ន្ធបរិក្ខារ និងស្ថាប័នសំរាប់គ្រប់គ្រងសំណល់រឹង | ក្រុមហ៊ុនសហប្រតិបត្តិការ-វិនិយោគប៉ុះ និងខេត្ត | | 1.000 | | |
| 37 | 3,4,5 6 | | SW-2 | ពង្រឹងប្រព័ន្ធប្រមូលសំរាម | ពង្រីកការប្រមូលសំរាមរឹងឱ្យបាន ១០០ % | ក្រុមហ៊ុនសហប្រតិបត្តិការ-វិនិយោគប៉ុះ និងខេត្ត | | 300 | | |
| 38 | 4,5,6 | | SW-3 | កន្លែងចាក់សំរាមអនាម័យ | លើកកំពស់ការអនុវត្តន៍នៅតាមកន្លែងចាក់សំរាមបច្ចុប្បន្ន និងផែនការសំរាប់កន្លែងថ្មី | ក្រុមហ៊ុនសហប្រតិបត្តិការ-វិនិយោគប៉ុះ និងខេត្ត | | 2.000 | | |
| 39 | 3,4,5 | ប្រព័ន្ធលូទឹក និងសំណល់រាវ | SD-1 | គំរោងអភិវឌ្ឍន៍ទេសចរណ៍មេគង្គ ក១ | លើកកំពស់ប្រព័ន្ធលូទឹកក្នុងក្រុង | សាធារណការ (ជំនួយADB) | | 11.968 | | |
| 40 | 3,4,5 | | SD-2 | គំរោងអភិវឌ្ឍន៍ក្រុងសៀមរាប | ពង្រឹងប្រព័ន្ធលូទឹក និងសំណល់រាវក្នុងតំបន់កណ្តាលក្រុង | ខេត្ត និង សាធារណការ (ជំនួយ AFD) | អាទិភាព | 4.800 | | |
| 41 | 3,4,5 | | SD-3 | ប្រព័ន្ធលូសំណល់រាវ ដំណាក់កាល ១ | ប្រព័ន្ធប្រមូលសំណល់រាវក្នុងកណ្តាលក្រុងភាគខាងលិច (តំបន់១) | ម. និងក្រសួងសាធារណការ | | 18.326 | | |
| 42 | 3,4,5 | | SD-4 | ប្រព័ន្ធលូសំណល់រាវ ដំណាក់កាល ២ | ប្រព័ន្ធប្រមូលសំណល់រាវក្នុងកណ្តាលក្រុងភាគខាងកើត និងរោងចក្រប្រព្រឹត្តិកម្មទឹក | ម. និងក្រសួងសាធារណការ | | 17.271 | | |
| 43 | 3,4,5 | | SD-5 | ការបញ្ចេញទឹកភ្លៀង | ប្រព័ន្ធលូទឹកក្នុងក្រុងថ្មីនៅភាគខាងលិច | ម. និងក្រសួងសាធារណការ | | 10.935 | | |
| 44 | 3,4,5 | | SD-6 | ការគ្រប់គ្រងសំណល់រាវ (ដំណាក់កាល ១) | រចនាប្រមូលសំណល់រាវ និងរោងប្រព្រឹត្តិកម្មសំរាប់ (SD-1) | ម. និងក្រសួងសាធារណការ | | 1.614 | | |
| 45 | 3,4,5 | | SD-7 | ការគ្រប់គ្រងសំណល់រាវ (ដំណាក់កាល ២) | រចនាប្រមូលសំណល់រាវ និងរោងប្រព្រឹត្តិកម្មសំរាប់ (SD-4) | ម. និងក្រសួងសាធារណការ | | 1.027 | | |
| 46 | 3,4,5 | | SD-8 | ការចោលសំណល់ បន្ទាប់ពីប្រព្រឹត្តិកម្ម ដំណាក់កាល ១ | សំរួលប្រព័ន្ធបំពង់សំរាប់ប្រមូល និងនាំទឹកបន្ទាប់ពីប្រព្រឹត្តិកម្មទៅកាន់អាងចំរោះ ដោយ SD-3 | ម. និងក្រសួងសាធារណការ | | 13.137 | | |
| 47 | 3,4,5 | | SD-9 | ការចោលសំណល់ បន្ទាប់ពីប្រព្រឹត្តិកម្ម ដំណាក់កាល ២ | សំរួលប្រព័ន្ធបំពង់សំរាប់ប្រមូល និងនាំទឹកបន្ទាប់ពីប្រព្រឹត្តិកម្មទៅកាន់អាងចំរោះ ដោយ SD-3 | ម. និងក្រសួងសាធារណការ | | 7.634 | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| 48 | 5,6 | ថាមពល | P-1 | ការបំពាក់ម៉ាស៊ីនភ្លើងម៉ាស៊ូតជាបន្ទាន់ | បំពាក់ម៉ាស៊ីនប្រេងម៉ាស៊ូតថ្មី គលាំងដែលមេហ្គាវ៉ាត់ នៅទីតាំងអគ្គិសនីកម្ពុជា | អគ្គិសនីកម្ពុជា | អាទិភាព | 2.090 | | |
| 49 | 5 | | P-2 | ពង្រីកស្ថានីយ៍ថាមពលប្រើម៉ាស៊ូតបម្រុង | ពង្រីកស្ថានីយ៍ថាមពលប្រើម៉ាស៊ូតឱ្យដល់កំរិត ១០ មេហ្គាវ៉ាត់ | អគ្គិសនីកម្ពុជា | | 20.800 | | |
| 50 | 5 | | P-3 | ពង្រីក និងបន្ថែមបណ្តាញចែកចាយ | បន្ថែមខ្សែដែលមានវ៉ុលទាប និងខ្ពស់ និងបន្ថែមអនុស្ថានីយ៍ និងនាឡិកាវាស់ម៉ោងថ្មីៗ | អគ្គិសនីកម្ពុជា | | 7.800 | | |
| 51 | 3,5 | | P-4 | បំពាក់ និងជួសជុលភ្លើងតាមផ្លូវ | កែលម្អភ្លើងតាមផ្លូវសំរាប់ភ្ញៀវទេសចរ | ស្រុក | | 780 | | |
| 52 | 1,3,6 | | P-5 | ប្រើប្រាស់អគ្គិសនីប្រកបដោយប្រសិទ្ធភាពខ្ពស់សំរាប់អគារ និងប្រាសាទផ្សេងៗ | បំភ្លឺមហោស្រពអង្គរដោយប្រភពភ្លើងសាធារណៈ | អប្សរា /ស្ថាប័នពាក់ព័ន្ធ | | 330 | | |
| 53 | 2,5 | | P-6 | ធ្វើផែនការផ្គត់ផ្គង់អគ្គិសនីដល់កន្លែងដែលគ្មានអគ្គិសនី | ពង្រីកតំបន់មានអគ្គិសនី នៅពេលមានការពង្រីកក្រុង | អគ្គិសនីកម្ពុជា | | 275 | | |
| 54 | 5,6 | | P-7 | ជំនួយដល់ការកសាងសមត្ថភាពសំរាប់អគ្គិសនីកម្ពុជា | បណ្តុះបណ្តាលវិស្វករពីអគ្គិសនីកម្ពុជានៅសៀមរាប | អគ្គិសនីកម្ពុជា | | 550 | | |
| 55 | 5,6 | | P-8 | ជំនួយដល់ការពិនិត្យឡើងវិញនូវអត្រាតំលៃភ្លើង | ផ្តល់អត្រាតំលៃភ្លើងទៅតាមប្រភេទអ្នកប្រើប្រាស់ | អគ្គិសនីកម្ពុជា/ អាជ្ញាធរអគ្គិសនីកម្ពុជា | | 990 | | |
| 56 | 5,6 | | P-9 | ពិនិត្យឡើងវិញនូវច្បាប់ បទបញ្ជា និងក្រឹត្យទាក់ទងអគ្គិសនីដើម្បីបន្ថយបន្ទុកបរិស្ថាន | ពិនិត្យ កែសំរួល និងអនុម័តច្បាប់ពាក់ព័ន្ធដើម្បីកាត់បន្ថយបន្ទុកបរិស្ថាន | ក្រុង អគ្គិសនីកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជា | | 1.800 | | |
| 57 | 5,6 | | P-10 | អភិវឌ្ឍប្រភពថាមពលចំរុះ | ស្វែងរកជំរើសសំរាប់ប្រភពថាមពល | អគ្គិសនីកម្ពុជា ថាមពល | | 660 | | |

| | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|
| | | រដ្ឋបាលមូលដ្ឋាន | (អនុសាសន៍) | | | | | | | |
| 58 | 6 | | L-1 | គណៈកម្មការអភិវឌ្ឍន៍សំរាប់អនុម័តគំរោង | បង្កើតគណៈកម្មការមួយសំរាប់ប្រតិបត្តិការរួមក្នុងខេត្ត | ខេត្ត | | 0 | | |
| 59 | 6 | | L-2 | អភិវឌ្ឍន៍ធនធានមនុស្សក្នុងខេត្ត | ការលើកកំពស់ចំណេះដឹងមន្ត្រីខេត្ត | ខេត្ត | | 1.600 | | |
| 60 | 6 | | L-3 | កំណែទំរង់ស្ថាប័ននៃអាជ្ញាធរខេត្តស.រ | ធ្វើឱ្យប្រសើរឡើងនូវចេនាសម្ព័ន្ធគ្រប់គ្រងនៅក្នុងខេត្ត | ខេត្តសៀមរាប | | | | |
| 61 | 6 | | L-4 | បង្កើត និងអនុវត្តច្បាប់ និងបទដ្ឋានច្បាប់ឱ្យមានប្រសិទ្ធភាព | រៀបចំក្របខ័ណ្ឌច្បាប់សំរាប់វិមជ្ឈការ | ខេត្ត ក្រសួងមហាផ្ទៃ | | | | |
| 62 | 6 | | L-5 | កំណែទំរង់ហិរញ្ញវត្ថុនៅថ្នាក់ខេត្តសំរាប់វិមជ្ឈការ | ពង្រឹងធនធានហិរញ្ញវត្ថុរបស់ខេត្តសៀមរាប | ក្រសួងហិរញ្ញវត្ថុ សភាជាតិ | | | | |
| 63 | 3,6 | ការចូលរួមរបស់សហគមន៍ | C-1 | ធ្វើផែនទីប្រើប្រាស់ដី | រៀបចំសិក្ខាសាលាដើម្បីធ្វើផែនទីក្នុងស្រុក | ខេត្ត ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 10 | | |
| 64 | 3,6 | | C-2 | ធ្វើផែនការសហគមន៍ | សិក្ខាសាលាធ្វើផែនការជាមួយភាគីពាក់ព័ន្ធនៅមូលដ្ឋាន | ខេត្ត ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 10 | | |
| 65 | 3,6 | | C-3 | សមាគមសហគមន៍ | សមាគមសហគមន៍ដើម្បីអនុវត្តគំរោង | ខេត្ត ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 10 | | |
| 66 | 2,3,6 | | C-4 | ការអនុវត្តការងារនៅតាមសហគមន៍ | អនុវត្តវិធីសាស្ត្រមីក្រូសំរាប់ធ្វើផែនការគំរោង | ខេត្ត ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 100 | | |
| 67 | 2,3,6 | | C-5 | ការត្រួតពិនិត្យអំពីការរស់នៅរួមគ្នារវាងអ្នកភូមិ និងទេសចរណ៍ | ផែនការសំរាប់តំបន់១ និង២របស់អប្សរាសំរាប់ឱ្យសហគមន៍អាចរស់នៅជាមួយនឹងបេតិកភណ្ឌ | អប្សរា ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 100 | | |
| 68 | 2,3,6 | | C-6 | ផែនការគ្រប់គ្រងអង្គរ និងការអភិវឌ្ឍន៍សហគមន៍ | លើកកំពស់ជីវភាពប្រជាជនដើម្បីរស់នៅសមរម្យជាមួយបេតិកភណ្ឌ | អប្សរា ឃុំ និងភាគីពាក់ព័ន្ធនៅមូលដ្ឋាន | | 3.000 | | |
| 69 | 3,6 | | C-7 | ស្វែងយល់ពីសុំរការរបស់ប្រជាជន | ប្រើប្រាស់ប្រព័ន្ធព័ត៌មានដើម្បីផ្សព្វផ្សាយសំលេងរបស់ប្រជាជន | ខេត្ត | | 1 | | |
| សរុប | | | | | | | | 310.633 | | |

ចំណាំ : ក្រឡោនដែលមានស្រមោលគឺជាគំរោង ឬកម្មវិធីដែលមានអាទិភាព

## ៦.២ លក្ខណវិនិច្ឆ័យ និងដំណើរការកំណត់គំរោង

### ៦.២១ លក្ខណវិនិច្ឆ័យ

គំរោង និងកម្មវិធីដែលបានស្នើឡើងខាងលើគឺជាគំរោងដែលមិនអាចខ្វះបានសំរាប់អភិវឌ្ឍន៍សៀមរាប។ ទោះជាយ៉ាងនេះក៏ដោយ ដោយផ្អែកលើក្របខ័ណ្ឌថវិការបស់ក្រុមសិក្សា ការសិក្សានេះចាំបាច់ត្រូវកំណត់គំរោង និងកម្មវិធីជាអាទិភាពក្នុងចំណោមគំរោង និងកម្មវិធីខាងលើ។ ដើម្បីកំណត់អាទិភាព ក្រុមសិក្សាបានធ្វើការពិនិត្យឡើងវិញនូវលំដាប់ជាក់ ស្តែងនៃចំណុចខ្លាំងបញ្ហាសំខាន់ៗ ចក្ខុវិស័យរួម និងយុទ្ធសាស្ត្រតាមវិស័យសំរាប់ការអភិវឌ្ឍន៍រយៈពេលវែង និងរយៈពេលខ្លី។ រយៈពេលសំរាប់អនុវត្តផែនការនេះគឺ១៥ ឆ្នាំ ពេលគឺពីឆ្នាំ២០០៦ ដល់ឆ្នាំ២០២០ ដែលឆ្នាំ ២០១២ គឺជាឆ្នាំកណ្តាលនៃផែនការនេះ។ ដូចនេះ

ក្រុមសិក្សាកំណត់រយៈពេលពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១១ ជារយៈពេលខ្លី និងរយៈពេលពីឆ្នាំ២០១២ ដល់២០២០ ជារយៈពេលវែង។

**វិស័យទេសចរណ៍នាំទៅរកការលើកកំពស់បរិស្ថាន និងសេដ្ឋកិច្ច ឆ្នាំ ២០២០**




**រូបទី ៦១ : ជំហានទាំង ៤ នៃការអភិវឌ្ឍន៍ រហូតដល់ឆ្នាំ ២០២០**

រូបខាងលើបង្ហាញពីទំនាក់ទំនងគ្នាស្មុគស្មាញដែលមិនអាចខ្វះបាននៃយុទ្ធសាស្ត្រនានា ដោយចាប់ផ្តើមពីឆ្នាំ ២០០៦ ដល់ឆ្នាំ ២០២០។ ទោះជាយ៉ាងនេះក៏ដោយ នៅក្នុងរបាយការណ៍មេ ក្រុមសិក្សាទៅលើជំហានអភិវឌ្ឍន៍ដូចមានបង្ហាញនៅក្នុងរូបទី៦១។

ជំហានទី ១ : ការធ្វើឱ្យក្រុងកាន់តែមានការទាក់ទាញថែមទៀតសំរាប់ភ្ញៀវទេសចរ។

ជំហានទី ២ ក : ការកែលំអបរិស្ថានក្រុង និងតាមលំនៅដ្ឋាន

ជំហានទី ២ ខ : ការពង្រីកតំបន់ទេសចរណ៍

ជំហានទី ៣ : ការអភិវឌ្ឍន៍តំបន់ប្រកបដោយនិរន្តរភាពដោយផ្អែកលើទេសចរណ៍គុណភាព

ការកំណត់ជំហាដូចនេះឆ្លុះបញ្ចាំងពីការកែប្រែលើការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍន៍ទូទៅនៃសៀមរាប។ អនុសាសន៍របស់ក្រុមសិក្សាស្រាវជ្រាវគឺថា ការអភិវឌ្ឍន៍ទេសចរណ៍ត្រូវតែដឹកនាំដោយក្រសួង/មន្ទីរទេសចរណ៍ និងការអភិវឌ្ឍន៍ទីកន្លែងត្រូវតែដឹកនាំដោយមជ្ឈមណ្ឌលក្រុងសំរាប់រយៈពេលខ្លី។ ការអភិវឌ្ឍន៍ទេសចណ៍ ឱ្យបានទូលំទូលាយនៅក្នុង និងជិតមជ្ឈមណ្ឌលក្រុងរយៈពេលខ្លីត្រូវតែធ្វើឡើងដោយការអភិវឌ្ឍន៍ទេសចរណ៍ឱ្យបាន ទូលំទូលាយនៅទូទាំងខេត្តសំរាប់រយៈពេលវែង និងមានឥទ្ធិពលខ្លាំងទៅលើសេដ្ឋកិច្ចមូលដ្ឋាន។ ទន្ទឹមគ្នានេះ ការអភិវឌ្ឍន៍ទេសចរណ៍ទូលំទូលាយនឹងត្រូវតែជាការអភិវឌ្ឍន៍ដែលចូលរួមដល់ការលើកកំពស់បរិស្ថានក្នុងតំបន់ក្រុងទាំងមូលសំរាប់ភ្ញៀវទេសចរ និងប្រជាជនមូលដ្ឋាន។ ក្រុមសិក្សាកំណត់ជំហានខាងលើដោយផ្អែកលើអនុសាសន៍នេះ។

កត្តាសំខាន់មួយទៀតក្នុងការកំណត់ជំហាននេះគឺការគ្រប់គ្រង និងហិរញ្ញវត្ថុសំរាប់ការងារអភិវឌ្ឍន៍ ដូចមានបង្ហាញក្នុងរូបទី៦១។ អនុសាសន៍របស់ក្រុមគឺថា គំនិតផ្តួចផ្តើមថ្មីណាមួយគួរតែយកចិត្តទុកដាក់ ដើម្បីពង្រឹងការគ្រប់គ្រង និងហិរញ្ញ

វត្ថុសំរាប់អភិវឌ្ឍន៍ និងគួរធ្វើឡើងនៅថ្នាក់ខេត្តដោយយកចិត្តទុកដាក់ទៅលើវិស័យទេសចរណ៍ និងក្រុងក្នុងរយៈពេលខ្លីជាជាង ការចាប់ផ្តើមនៅថ្នាក់ឃុំដែលយកចិត្តទុកដាក់ទៅលើវិស័យជនបទ។ ការអភិវឌ្ឍន៍ក្នុងខេត្តសៀមរាបត្រូវតែដឹកមុខដោយ វិស័យទេសចរណ៍ និងក្រុងដែលការនេះខុសគ្នាពីតំបន់ផ្សេងៗ ទៀតក្នុងប្រទេសកម្ពុជា ដែលការអភិវឌ្ឍន៍ត្រូវធ្វើឡើងនៅ តំបន់ជនបទ។

យោងតាមដំណើរនៃការអភិវឌ្ឍន៍រួម ដូចមានបង្ហាញក្នុងរូបទី៦១ ក្រុមសិក្សាបានពិនិត្យបញ្ជីគំរោង និងកម្មវិធីដែល បានស្នើឡើងម្តងមួយៗ ដោយផ្អែកលើចំណុចពីរគឺ :

- សារៈសំខាន់រយៈពេលខ្លី
- រយៈសំខាន់រយៈពេលវែង

នេះបង្ហាញពីការដាក់បញ្ចូលគ្នារវាងសារៈសំខាន់នៃគំរោង និងកម្មវិធីរយៈពេលខ្លី និងវែង។

(១) សារៈសំខាន់រយៈពេលខ្លី

គំរោងមួយអាចមានអាទិភាពរយៈពេលខ្លី ដោយសារគំរោងនោះមានភាពចាំបាច់ ហើយអាចអនុវត្តមានប្រសិទ្ធភាព រយៈពេលខ្លី។

(២) សារៈសំខាន់រយៈពេលវែង

គំរោងមួយមានអាទិភាពរយៈពេលវែង ដោយសារគំរោងនោះ :

- ឆ្លុះបញ្ចាំងផ្ទាល់ពីគោលគំនិតនៃផែនការមេ
- ជាការចាំបាច់ដើម្បីនាំទៅរកភាពជោគជ័យនៃផែនការមេក្នុងរយៈពេលយូរ និង
- ត្រូវការអនុវត្តន៍មុន បើពិនិត្យទៅលើរយៈពេលរៀបចំដ៏យូរ។

### ៦.២.២ គំរោងអាទិភាព

ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យខាងលើ ផ្នែកនេះលើកឡើងពីគំរោង និងកម្មវិធីអាទិភាព។

**តារាង ១៦ : គំរោង និងកម្មវិធីអាទិភាព (១/២)**

| វិស័យ | លេខសំគាល់ | ឈ្មោះគំរោង | រយៈពេលអនុវត្តគំរោង | សារៈសំខាន់ | | ការផ្តល់ហេតុផល |
|---|---|---|---|---|---|---|
| | | | | រយៈពេលខ្លី | រយៈពេលវែង | |
| ក្រុង | U-1 | កែលំអតំបន់កណ្តាលក្រុង | 2006-2007 | X | | ការកែប្រែមុខមាត់ថ្មី ដើម្បីលើកកំពស់បរិស្ថានក្រុង /ទេសចរណ៍ ក្នុង មណ្ឌលក្រុងដោយសង្កត់ធ្ងន់លើតំបន់ក្បែរផ្សារចាស់ |
| ក្រុង | U-2 | ការកសាងមត្ថភាពធ្វើផែនការក្រុង | 2006-2007 | | X | យុទ្ធសាស្ត្រដើម្បីដាក់បញ្ចូល និងពង្រឹងគោលនយោបាយ /ការគ្រប់គ្រងក្រុងក្នុងរដ្ឋបាលខេត្ត។ ការងារជាចំបងនោះគឺការកែលំអផែនការ/ការគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងគណៈកម្មការនៅថ្នាក់ឱ្យកាន់តែមានប្រសិទ្ធភាពឡើងសំរាប់ការរៀបចំផែនការក្រុង។ |

| | | | | | | |
|---|---|---|---|---|---|---|
| បរិស្ថាន | E-2 | ការលើកកំពស់ចំណេះដឹងបរិស្ថាន | 2006-2012 | | X | ជាការសំខាន់គឺត្រូវបន្តធ្វើឱ្យគំរោងសាកល្បង "ធ្វើឱ្យសៀមរាបកាន់តែស្រស់ស្អាតឡើង" កាន់តែមាននិរន្តរភាព និងទូលំទូលាយ ។ |
| ទេសចរណ៍ | TO-1 | បណ្តាញទេសចរណ៍បេតិកភណ្ឌខ្មែរ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសំរាប់ទេសចរណ៍ | 2007-2012 | X | | ការស្វែងរកតំលៃនៃវប្បធម៌ខ្មែរឡើងវិញគឺជាការចាំបាច់ ។ |
| ទេសចរណ៍ | TO-3 | ការលើកកំពស់គុណភាពទេសចរណ៍តាមរយៈភាពជាដៃគូសាធារណៈ-ឯកជន | 2006-2020 | X | | ត្រូវមានកម្មវិធីសំខាន់មួយដើម្បីសំរបសំរួលភ្ញៀវទេសចរគំរោងផ្សេងៗ ដើម្បីគ្រប់គ្រងផ្នែកឯកជនជាមុន និងដើម្បីលើកកំពស់គោលដៅទីផ្សារទេសចរណ៍ |
| ការពង្រីកកសិកម្ម និងផលិតផលក្នុងស្រុក | A-1 | អភិវឌ្ឍន៍ធនធានមនុស្ស និងមជ្ឈមណ្ឌលលើកកំពស់ផលិតផល | 2006-2008 | X | X | ជាការសំខាន់ដើម្បីធ្វើឱ្យគំរោងសាកល្បង "ការតាំងពិពណ៌ផលិតផលអង្គរ" កាន់តែមាននិរន្តរភាពដោយការពង្រឹងមជ្ឈមណ្ឌលលើកកំពស់ផលិតផលអង្គរ ។ |
| មធ្យោបាយដឹកជញ្ជូន | TR-1 | កែលំអស្ពានបារាំង | 2006-2012 | X | X | ជាការសំខាន់ក្នុងការភ្ជាប់លទ្ធភាពធ្វើដំណើរពីភាគខាងកើត និងខាងលិចក្រុង ដោយរក្សាទុកនូវស្ពានបច្ចុប្បន្ន |
| មធ្យោបាយដឹកជញ្ជូន | TR-2 | បណ្តាញផ្លូវរណបប្រទាក់ក្រឡា (ដំណាក់១) | 2006-2008 | X | X | ការសំរួលជាបន្ទាន់កុំឱ្យមានការកកស្ទះតាមបណ្តោយផ្លូវជាតិ លេខ ៦ គឺជាការសំខាន់ |
| មធ្យោបាយដឹកជញ្ជូន | TR-7 | ការស្តារបណ្តាញផ្លូវ ទៅកាន់កន្លែងបេតិកភណ្ឌនៅតាមតំបន់ឆ្ងាយៗ | 2006-2009 | X | X | ជាការចាំបាច់មិនអាចខ្វះបានដើម្បីលើកកំពស់ភាព សម្បូរបែបនៃកន្លែងទាក់ទាញភ្ញៀវទេសចរ និងធានាដល់ការធ្វើដំណើរងាយស្រួលទៅកាន់រមណីយដ្ឋាន ប្រវត្តិសាស្ត្រផ្សេងៗ |

**តារាង ១៧ : គំរោង និងកម្មវិធីអាទិភាព (២/២)**

| វិស័យ | លេខសំគាល់ | ឈ្មោះគំរោង | រយៈពេលអនុវត្តគំរោង | សារៈសំខាន់ | | ការផ្តល់ហេតុផល |
|---|---|---|---|---|---|---|
| ទឹក | W-3 | ការជំនួសបំពង់ទឹកដែលមិនប្រើប្រាស់ | 2006-2007 | X | | គឺជាការចាំបាច់ដើម្បីដាក់ជំនួសបំពង់ទឹកចាស់ៗក្នុងប្រព័ន្ធទឹកបច្ចុប្បន្នសំរាប់ដំណើរការចែកចាយទឹកពីគំរោងបែងចែកទឹកថ្មីប្រកបដោយប្រសិទ្ធភាព ។ |

| | | | | | | |
|---|---|---|---|---|---|---|
| ទឹក | W-4 | សិក្សាតាមបែបយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងធនធានទឹករួមសំរាប់ស្ទឹងសាប និងរលួស | 2007-2011 | X | X | យុទ្ធសាស្ត្រ និងភាពចាំបាច់ដើម្បីកំណត់វិធី និងមធ្យោបាយដើម្បីជំនួសការបូមទឹកក្រោមដីតាមកន្លែងនីមួយៗដោយការផ្គត់ផ្គង់ទឹកសាធារណៈជាបណ្តើរៗ និងធានាការគ្រប់គ្រងទឹករយៈវែងសំរាប់អ្នកប្រើប្រាស់ និងកន្លែងផ្សេងៗ ក្នុងស្រុកសៀមរាប |
| ប្រព័ន្ធបង្ហូរសំណល់រាវ/ទឹក | SD-2 | ការអភិវឌ្ឍន៍ប្រព័ន្ធបង្ហូរសំណល់រាវ និងទឹក | 2006-2020 | X | | ជាការសំខាន់ក្នុងការកែលំអអនាម័យ និងបរិស្ថាននៅតាមតំបន់កណ្តាលក្រុង ជាកន្លែងនៃរមណីយដ្ឋានទេសចរណ៍ និងការរស់នៅរបស់ប្រជាជន ។ គំរោងដែលបានទទួលជំនួយពី ADB មានផែនការបង្កើតរោងចក្រប្រព្រឹត្តិកម្មទឹកសំរាប់គោលដៅអនាម័យ និងបរិស្ថាននេះ ។ |
| អគ្គីសនី | P-1 | ការបំពាក់ជាបន្ទាន់នូវម៉ាស៊ីនប្រើម៉ាស៊ូត | 2006-2007 | X | X | មានប្រសិទ្ធភាពខ្ពស់ និងងាយស្រួលប្រតិបត្តិការ ដែលជាវិធានការបន្ទាន់ដើម្បីកាត់បន្ថយជំងឺដាច់ភ្លើងរ៉ាំរ៉ៃ |

តារាងខាងក្រោមគឺជាសេចក្តីសង្ខេបពីការចំណាយសរុបនៃគំរោងគ្មាន និងមានអាទិភាព ។

**តារាង ១៨ : គំរោង និងកម្មវិធីអាទិភាព និងការប៉ាន់ស្មានតំលៃគំរូង**

| វិស័យ | | គំរោងអាទិភាព | | គំរោងផ្សេងៗ | | សរុប | |
|---|---|---|---|---|---|---|---|
| | | ចំនួន | តំលៃគំរោង (000 ដុល្លារ) | ចំនួន | តំលៃគំរោង (000 ដុល្លារ) | ចំនួន | តំលៃគំរោង (000 ដុល្លារ) |
| ការអភិវឌ្ឍន៍ក្រុង | U-1 ទៅ 5 | 2 | 8.100 | 3 | 200 | 5 | 8.300 |
| ការគ្រប់គ្រងបរិស្ថាន | E-1 ទៅ 3 | 1 | 330 | 2 | 620 | 3 | 950 |
| ទេសចរណ៍ | TO-1 ទៅ 6 | 2 | 26.550 | 4 | 792 | 6 | 27.342 |
| ការពង្រីកកសិកម្ម និងផលិតផលក្នុងស្រុក | A-1 ទៅ 4 | 1 | 80 | 3 | 204 | 4 | 284 |
| មធ្យោបាយដឹកជញ្ជូន | TR-1 ទៅ 10 | 3 | 44.946 | 7 | 55.795 | 10 | 100.741 |
| ទឹក | W-1 ទៅ 7 | 2 | 7.732 | 5 | 34.346 | 7 | 42.078 |
| សំណល់រឹង | SW-1 ទៅ 3 | | | 3 | 3.300 | 3 | 3.300 |
| ប្រព័ន្ធបង្ហូរសំណល់រាវ/ទឹក | SD-1 ទៅ 9 | 1 | 4.800 | 8 | 81.932 | 9 | 86.732 |
| អគ្គីសនី | P-1 ទៅ 10 | 1 | 2.090 | 9 | 33.985 | 10 | 36.075 |
| រដ្ឋបាលមូលដ្ឋាន | L-1 ទៅ 5 | | | 5 | 1.600 | 5 | 1.600 |
| ការផ្តល់សិទ្ធិអំណាចដល់ស.គ | C-1 ទៅ 7 | | | 7 | 3.231 | 7 | 3.321 |
| សរុប | | 13 | 94.628 | 56 | 216.205 | 69 | 310.633 |

## ៦.៣ កញ្ចប់អភិវឌ្ឍន៍

គំរោង និងកម្មវិធីនានាដែលបានលើកឡើងខាងលើគឺជាផ្នែកនៃផែនការមេ។ តារាង១៩ ខាងក្រោម គឺជាការបញ្ជាក់ឡើងវិញនូវយុទ្ធសាស្ត្រគាំទ្រដល់គំរោង និងកម្មវិធីទាំងនោះ។

**តារាង ១៩ : គំរោង និងកម្មវិធីតាមយុទ្ធសាស្ត្រ និងតំបន់**

| | គ្រប់តំបន់ទាំងអស់ | ក្រុង | ឆ្នេរ/បេតិកភណ្ឌ | | ទន្លេសាប |
|---|---|---|---|---|---|
| | | | ឆ្នេរ | បេតិកភណ្ឌ | |
| **យុទ្ធសាស្ត្រទី ១ :** ការលើកកំពស់ទេសចរណ៍ដោយគំរង់ទិសទេសចរមានគិរិតចំណាយខ្ពស់ | TO-3 | | | TO-1 | |
| **យុទ្ធសាស្ត្រទី ២ :** ការពង្រីកផលប្រយោជន៍មូលដ្ឋានឱ្យដល់កំរិតអតិបរមា | TO-5, A-1 | A-4 | TO-5,A-2~4 | TO-1 | TO-5 |
| **យុទ្ធសាស្ត្រទី ៣ :** ការធ្វើឱ្យក្រុងក្លាយជាកន្លែងទាក់ទាញសំរាប់ភ្ញៀវទេសចរ | | TO-2, A-4, TR-8 | | | |
| **យុទ្ធសាស្ត្រទី ៤ :** ការធ្វើឱ្យក្រុងកាន់តែមាននិរន្តរភាពខាងបរិស្ថាន | W-1,4,6 | TR-8~9, W-2,3, SW-1~3, SD-1~9, P-10 | | | W-5 |
| **យុទ្ធសាស្ត្រទី ៥ :** ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសំរាប់ភ្ញៀវទេសចរ និងប្រជាជន | TR-10 | TR-1~5, W-5,7, P-1~4, 8 | P-6 | P-5 | |
| **យុទ្ធសាស្ត្រទី ៦ :** ការពង្រឹងរដ្ឋបាល និងហិរញ្ញវត្ថុមូលដ្ឋាន | A-1, TR-6, C-7 | W-1, P-9, C-1~4 | TR-7 | C-5~6 | |

ជាចុងក្រោយ តារាងខាងលើត្រូវបានបែងចែកជាក្រុមនៃ "កញ្ចប់អភិវឌ្ឍន៍"។ កញ្ចប់អភិវឌ្ឍន៍នេះមានគំរោង និងកម្មវិធីក្នុងតារាង១៩ និងមានគោលបំណងធ្វើឱ្យសំរេចជោគជ័យនៃយុទ្ធសាស្ត្រទាំង៦ ដោយប្រើប្រាស់វិធីសាស្ត្ររួមគ្នា (តារាង ២០)។

## តារាង ២០ : កញ្ចប់អភិវឌ្ឍន៍

| | គ្រប់តំបន់ទាំងអស់ | ក្រុង | ជនបទ/បេតិកភណ្ឌ: ជនបទ | ជនបទ/បេតិកភណ្ឌ: បេតិកភណ្ឌ | ទន្លេសាប |
|---|---|---|---|---|---|
| **យុទ្ធសាស្ត្រទី ១ :** ការលើកកំពស់ទេសចរណ៍ដោយតំរង់ទិសទេសចរមានគិរិតចំណាយខ្ពស់ | ការគាំទ្រលើការលើកកំពស់ទេសចរណ៍ | | | | |
| **យុទ្ធសាស្ត្រទី ២ :** ការពង្រីកផលប្រយោជន៍មូលដ្ឋានឱ្យដល់គិរិតអតិបរមា | ការបង្កើតផលិតក្នុងស្រុក | | | នាំគ្នាលើកកំពស់រមណីយដ្ឋានបេតិកភណ្ឌ | ការលើកកំពស់ទេសចរណ៍ធម្មជាតិ |
| **យុទ្ធសាស្ត្រទី ៣ :** ការធ្វើឱ្យក្រុងក្លាយជាកន្លែងទាក់ទាញសំរាប់ភ្ញៀវទេសចរ | | ការអភិវឌ្ឍន៍ក្រុងទេសចរណ៍<br>ការលើកកំពស់តំបន់រស់នៅ | | | |
| **យុទ្ធសាស្ត្រទី ៤ :** ការធ្វើឱ្យក្រុងកាន់តែមាននិរន្តរភាពខាងបរិស្ថាន | ការអភិវឌ្ឍន៍ធនធានទឹករួមគ្នា | ការអភិវឌ្ឍន៍ក្រុង | Greening/ Tree Planting | | |
| **យុទ្ធសាស្ត្រទី ៥ :** ការពង្រឹងហេដ្ឋារចនាសម្ព័ន្ធសំរាប់ភ្ញៀវទេសចរ និងប្រជាជន | | លើកកំពស់ហេដ្ឋា-រចនាសម្ព័ន្ធ | ការកែលំអផ្លូវទៅកាន់រមណីដ្ឋាននានា | | |
| **យុទ្ធសាស្ត្រទី ៦ :** ការពង្រឹងរដ្ឋបាល និងហិរញ្ញវត្ថុមូលដ្ឋាន | ការកសាងសមត្ថភាពសំរាប់ការអភិវឌ្ឍន៍ក្រុង/ខេត្ត | | | | |

## ៧. ការរៀបចំស្ថាប័ន និងហិរញ្ញវត្ថុ

ដើម្បីធ្វើឱ្យជោគជ័យនូវផែនការតាមវិស័យដែលបានលើកឡើងក្នុងគំរោង/កម្មវិធី ក្រុមសិក្សាស្នើឡើងអនុសាសន៍មួយចំនួនពាក់ព័ន្ធនឹងការរៀបចំស្ថាប័ន និងហិរញ្ញវត្ថុ។ អនុសាសន៍ទាំងនោះរួមមាន (១)អនុសាសន៍សំរាប់ស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ខេត្ត និងអនុសាសន៍សំរាប់ក្រសួងនៅថ្នាក់ជាតិ។

### ១. អនុសាសន៍សំរាប់ស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ខេត្ត

បញ្ហាជាគន្លឹះគឺត្រូវពង្រឹងគំនិតផ្តួចផ្តើម និងអាជ្ញាធររបស់អភិបាលខេត្តជាជំហាន១។ ខាងក្រោមនេះគឺជាអនុសាសន៍សំខាន់ៗសំរាប់ស្ថាប័នរដ្ឋាភិបាលនៅថ្នាក់ខេត្ត។

ក. ធានាឱ្យមានការចែករំលែកព័ត៌មាន និងការយល់ដឹងរួមអំពីគោលនយោបាយ ផែនការ ថវិកា និងគំរោងនានា ក្នុងស្រុកសៀមរាបរវាងសាលាខេត្ត មន្ទីរពាក់ព័ន្ធក្នុងខេត្ត និងអាជ្ញាធរអប្សរា។ ការនេះនឹងធ្វើឱ្យការសំរបសំរួល និងការសំរេចចិត្តរបស់អភិបាលខេត្តលើសកម្មភាពអភិវឌ្ឍន៍ក្នុងខេត្តសៀមរាបកាន់តែមានភាពរលូន។

ខ. ធានាឱ្យមានអាជ្ញាធរជាក់លាក់មួយដើម្បីអនុញ្ញាត/ហាមឃាត់សកម្មភាពឯកជននៅក្នុងវិស័យជាអាទិភាពមួយចំនួនដូចជា :

- ការប្រើប្រាស់ដី និងការគ្រប់គ្រងសំណង់
- ការត្រួតពិនិត្យបរិស្ថាន និង
- ការប្រើប្រាស់ធនធានទឹក ទាំងទឹកក្រោមដី និងទឹកលើដី

គ. ពង្រឹងមុខងារនៃការបង្កើតគោលនយោបាយក្រុង និងការគ្រប់គ្រងក្រុង : ជាទូទៅ អាជ្ញាធរខេត្តក្នុងប្រទេសកម្ពុជាទទួលខុសត្រូវលើការងារអភិវឌ្ឍន៍ជនបទ និងកសិកម្ម។ ទោះជាយ៉ាងនេះក៏ដោយ ដោយសារសេដ្ឋកិច្ច និងសង្គមរបស់ស្រុកសៀមរាបមានទំនាក់ទំនងយ៉ាងខ្លាំងលើការអភិវឌ្ឍន៍ក្រុង និងការអភិវឌ្ឍន៍ទេសចរណ៍ ដូចនេះគោលនយោបាយក្រុង និងការគ្រប់គ្រងក្រុងគួរផ្តួចផ្តើមឡើងនៅថ្នាក់ខេត្ត។

ឃ. ពង្រឹងគំនិតផ្តួចផ្តើមរបស់ខេត្តដើម្បីធានាឱ្យមានការចូលរួមយ៉ាងមានប្រសិទ្ធភាពពីផ្នែកឯកជន : ដោយសារសមត្ថភាពរដ្ឋាភិបាលនៅថ្នាក់ខេត្តមានកំរិត ការចូលរួមពីផ្នែកឯកជនគឺជាការចាំបាច់។ ទោះជាយ៉ាងនេះក៏ដោយតាមការសង្កេតនៅពេលបច្ចុប្បន្ន ការពឹងអាស្រ័យដែលមិនទទួលខុសត្រូវលើការចូលរួមពីផ្នែកឯកជដោយគ្មានផែនការ និងការត្រួតពិនិត្យពីសាធារណៈបណ្តាល ឱ្យមានការប្រើប្រាស់ធនធានសាធារណៈមិនសមស្របដើម្បីបំរើផលប្រយោជន៍ឯកជន និងការធ្លាក់ចុះនូវគុណភាពសេវាកម្ម ដែលប្រហែលជាអាចនាំទៅដល់ការបាត់បង់ផលប្រយោជន៍ សាធារណៈ និងដល់ការបរាជ័យលើការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។

ដើម្បីធ្វើឱ្យសំរេចអានុសាសន៍ទាំងនេះ ជាដំបូង ចាំបាច់ពង្រឹងមូលដ្ឋានស្ថាប័ននៅថ្នាក់ខេត្តដោយប្រើប្រាស់វិធានការដូចខាងក្រោម :

១) ពង្រឹងអាជ្ញាធរថ្នាក់ខេត្ត ដោយយកចិត្តទុកដាក់ទៅលើ

- ធនធានមនុស្សលើជំនាញបច្ចេកទេស និងគ្រប់គ្រង

- មូលដ្ឋានហិរញ្ញវត្ថុ សំរាប់ចំណាយប្រតិបត្តិ និង
- មូលដ្ឋានទិន្នន័យដើម្បីសំរួលដល់ការត្រួតពិនិត្យការប្រើប្រាស់ដី បរិស្ថាន ការប្រើប្រាស់ទឹក និងសេវាកម្មសាធារណៈឱ្យមានប្រសិទ្ធភាព ។

២) លើកកំពស់ការរៀបចំឱ្យមានការចូលរួមពីផ្នែកឯកជន

ការរៀបចំឱ្យមានការចូលរួមពីផ្នែកឯកជនគួរធ្វើឡើងដោយផ្អែកលើមូលដ្ឋានតម្លាភាព និងការប្រកួតប្រជែង ដើម្បីធានាភាពយុត្តិធម៌ គណនេយ្យភាព និងប្រសិទ្ធភាពនៃសេវាកម្មដែលបានផ្ដល់ជូន ស្របតាមផែនការអភិវឌ្ឍន៍ចិរភាព ។

៣) វិស័យដែលស្នើឱ្យមានការចូលរួមពីផ្នែកឯកជន

វិស័យមួយចំនួនដែលស្នើឱ្យមានការចូលរួមពីផ្នែកឯកជនរួមមាន ការប្រមូលសំណល់រឹង ការផ្សព្វផ្សាយ/លើកកំពស់ផលិតផលក្នុងស្រុក ការកសាងចំណេះដឹងក្នុងការលើកកំពស់បរិស្ថាន និងការផ្សព្វផ្សាយទេសចរណ៍ ។

## ២. អនុសាសន៍សំរាប់ក្រសួងនៅថ្នាក់ជាតិ

បញ្ហាជាគន្លឹះនោះគឺត្រូវពង្រឹងសមត្ថភាពទាក់ទងនឹងវិស័យច្បាប់ និងជំនាញរបស់ក្រសួងពាក់ព័ន្ធដើម្បីជួយអនុវត្តគំនិតផ្ដួចផ្ដើម និងអាជ្ញាធរខេត្តដូចបានលើកឡើងខាងលើ ។ អនុសាសន៍សំខាន់មានដូចខាងក្រោម :

ក. បង្កើត និងបកស្រាយច្បាប់ លិខិតបទដ្ឋានច្បាប់ និងនីតិវិធីក្នុងផ្នែកសំខាន់ៗ ដូចជា ការគ្រប់គ្រងលើការប្រើប្រាស់ដីធ្លី និងបរិស្ថាន ការគ្រប់គ្រងទឹក ។ ជាមួយគ្នានេះ ចាំបាច់ត្រូវពិនិត្យ និងធ្វើឱ្យរលូនក្នុងការបែងចែកការទទួលខុសត្រូវរវាងក្រសួង និងមន្ទីរពាក់ព័ន្ធ នៅតាមផ្នែកជាអាទិភាពទាំងនោះ

ខ. ពង្រឹងសមត្ថភាពបច្ចេកទេសរបស់ក្រសួង និងនាយកដ្ឋានពាក់ព័ន្ធ ដើម្បីជួយអភិបាលខេត្តប្រើប្រាស់គនិតផ្ដួចផ្ដើម និងអាជ្ញាធរខេត្តប្រកបដោយប្រសិទ្ធភាព ដោយសង្កត់ធ្ងន់ទៅលើការគ្រប់គ្រងដីធ្លី បរិស្ថាន និងទឹក ។

គ. គួរមានការកែទំរង់ពន្ធជាបន្ទាន់សំរាប់ជួយដល់ការអភិវឌ្ឍន៍មូលដ្ឋាន រួមទាំងការអភិវឌ្ឍន៍ក្នុងស្រុកសៀមរាប ។ ការខិតខំប្រឹងប្រែងដែលកំពុងធ្វើផ្សេងៗគួរតែធ្វើសេចក្ដីសំរេចឱ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើបាន ។

ការសិក្សាផែនការមេនេះបានស្នើគំរោងចំនួន៦៩ នៅតាមវិស័យផ្សេងៗ ។ តំលៃសរុបរបស់គំរោងមានចំនួន៣១១ លានដុល្លារ ។ គំរោង១៣ ក្នុងចំណោមគំរោងទាំងអស់ត្រូវបានចាត់ទុកជាគំរោងមានអាទិភាពសំរាប់អនុវត្តក្នុងរយៈពេល ៥ ឆ្នាំខាងមុខ ។ *គំរោងដែលមានអាទិភាពខ្ពស់ទាំងនោះត្រូវការចំណាយទឹកប្រាក់ប្រមាណជា៩៦ លានដុល្លារ ។*

ផ្ទុយទៅវិញ ទំហំថវិកាជាតិសរុបមានចំនួន៧២៣ លានដុល្លារ ។ ថវិកាចំនួន ២៣៣ដុល្លារក្នុងចំណោមថវិកាទាំងនោះត្រូវបានប្រើប្រាស់សំរាប់ការចំណាយទុនក្នុងឆ្នាំ ២០០៤ ។ ឧបមាថា ថវិកាជាតិនឹងត្រូវតម្លើងក្នុងអត្រាប្រចាំឆ្នាំ *៥% ចាប់ពីឆ្នាំ២០០៦ ដល់ឆ្នាំ២០២០ (អត្រាតម្លើងប្រចាំឆ្នាំជាមធ្យមពីឆ្នាំ២០០០ ដល់ឆ្នាំ២០០៤គឺ៨%)* នោះចំនួនសរុបនៃការចំណាយទុនជាតិអាចមានរហូតដល់ ៥.០៣៣លានដុល្លារ ។ ចំណាយសរុបរបស់គំរោងដែលមានចំនួន៣១១ លានដុល្លារគឺស្មើនឹង៦.២%នៃថវិកា៥.០៣៣ លានដុល្លារ ។ ចំនួននេះតិចជាងចំណែករបស់សៀមរាប ដែលមានចំនួន ៦,៧%នៅឆ្នាំ២០០៤ ។

ដូចនេះ តំរូវការ និងថវិកាដែលមានមិនអាចយកមកប្រៀបធៀបគ្នាក្នុងរបាយការណ៍នេះឡើយ ជាពិសេសពីព្រោះ

ហិរញ្ញវត្ថុដែលមិនមែនជារបស់រដ្ឋមិនបានគិតបញ្ចូល បើពិនិត្យទៅលើថវិកាដែលមាន។ ហិរញ្ញវត្ថុពីខាងក្រៅមានចំនួន ៧៥%នៃការចំណាយទុនសរុបថ្នាក់ជាតិនៅឆ្នាំ២០០៤។ ការនេះបញ្ជាក់យ៉ាងច្បាស់ថា ការពឹងផ្អែកលើហិរញ្ញវត្ថុបរទេស សំរាប់ការចំណាយទុននឹងអាចមានកំរិតធ្ងន់ធ្ងរ នៅពេលធ្វើការគិតគូរពីហិរញ្ញវត្ថុដែលមិនមែនជារបស់រដ្ឋ។ តាមការគិតគូរ នេះ គេអាចធ្វើការប៉ាន់ស្មានពីតួលេខទាំងនេះបានថា តំរូវការហិរញ្ញវត្ថុសំរាប់គំរោងដែលបានស្នើឡើងមិនហួសពីវង្វង់ថវិកា ដែលមានឡើយ។

ជាមួយគ្នានេះ គេអាចនិយាយបានថា សៀមរាបក៏នឹងអាចពឹងផ្អែកទៅលើហិរញ្ញវត្ថុខាងក្រៅយ៉ាងខ្លាំងផងដែរ។ ផ្អែកតាមអនុសាសន៍ទាំងឡាយខាងលើ និងសេចក្តីត្រូវការចាំបាច់ដែលមិនអាចខ្វះបានសំរាប់ធាតុបញ្ចូលពីខាងក្រៅ ការយកចិត្តទុកដាក់គួរធ្វើឡើងទៅលើបញ្ហាសំខាន់ៗពីរសំរាប់ការវិភាគឱ្យបានស៊ីជំរៅ និងសំរាប់សំណើសុំផ្សេងៗ (១)ការគ្រប់គ្រងការអភិវឌ្ឍន៍ជាពិសេសនៅថ្នាក់ខេត្ត និង(២)ហិរញ្ញវត្ថុនៅមូលដ្ឋាន។

## ៧.១ ការគ្រប់គ្រងការអភិវឌ្ឍន៍

### ៧.១. បញ្ហា

បញ្ហាដែលធ្ងន់ធ្ងរបំផុតនោះគឺថា ការគ្រប់គ្រងការអភិវឌ្ឍន៍របស់ខេត្តសៀមរាប ជាពិសេស អាជ្ញាធរខេត្តពុំមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តន៍ ឬសំរបសំរួលសកម្មភាពអភិវឌ្ឍន៍តាមលក្ខណៈឯកភាពគ្នានៅឡើយ។ ខាងក្រោមនេះគឺជាបញ្ហាសំខាន់ៗមួយចំនួន :

- ការត្រួតគ្នានៃភារកិច្ច និងការទទួលខុសត្រូវក្នុងចំណោមស្ថាប័នក្នុងរដ្ឋាភិបាល
- កង្វះការធ្វើសមាហរណកម្មក្នុងការគ្រប់គ្រងការអភិវឌ្ឍន៍នៅថ្នាក់ខេត្ត
- ធនធានហិរញ្ញវត្ថុមិនគ្រប់គ្រាន់
- សមត្ថភាពគ្រប់គ្រងមានកំរិត
- កង្វះក្របខ័ណ្ឌច្បាប់ជាខ្សែសង្វាក់ និងការពង្រឹងក្របខ័ណ្ឌច្បាប់នោះ

រចនាសម្ព័ន្ធបញ្ហាស្តីពីការគ្រប់គ្រងការអភិវឌ្ឍន៍នៅថ្នាក់ខេត្តត្រូវបានលើកយកមកវិភាគដូចមាននៅក្នុងរូបទី៦២។




**រូបទី ៦២ : បញ្ហា និងមូលហេតុនៃបញ្ហាទាក់ទងនឹងរដ្ឋបាលមូលដ្ឋាននៅថ្នាក់ខេត្ត**

គួរកត់សំគាល់ថា នៅពេលបច្ចុប្បន្ន គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការត្រូវបានគេពិភាក្សាយ៉ាងទូលំទូលាយនៅទូទាំងប្រទេសកម្ពុជា ។ ក្រសួងមហាផ្ទៃកំពុងតែព្រាងច្បាប់អង្គការសំរាប់រដ្ឋាភិបាលក្រោមថ្នាក់ជាតិ ហើយច្បាប់នេះនឹងត្រូវព្រាងបញ្ចប់នៅខែមីនា ឆ្នាំ២០០៦ ។ បើសិនអនុវត្តបានជោគជ័យនូវកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការនោះ ទំនាក់ទំនងរវាងរដ្ឋាភិបាលថ្នាក់ជាតិ និងខេត្ត និងរវាងរដ្ឋាភិបាលថ្នាក់ខេត្ត និងមន្ទីរជំនាញនឹងមានការកែប្រែមុខមាត់ថ្មីស្រឡាង ។

### ៧.១.២ យុទ្ធសាស្ត្រ

យុទ្ធសាស្ត្រទាំង៥ ខាងក្រោម ត្រូវបានកំណត់ដោយពិចារលើបញ្ហានានាសំរាប់ការគ្រប់គ្រងការអភិវឌ្ឍន៍ក្នុងខេត្តសៀមរាប ។

### យុទ្ធសាស្ត្រ ក : អនុវត្តរដ្ឋបាលឯកភាពដោយអនុលោមទៅតាមកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ

នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃឯកសារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលចេញដោយរាជរដ្ឋាភិបាល

កម្ពុជា ទស្សនៈនៃវដ្ឋបាលឯកភាពទទួលបានការគាំទ្រយ៉ាងខ្លាំងថាជាគោលការណ៍នៃប្រព័ន្ធរដ្ឋបាលមូលដ្ឋាន។ ការដាក់ឱ្យប្រើប្រាស់យន្តការឯកភាពសំរាប់ធានាឱ្យមានរដ្ឋបាលមានប្រសិទ្ធភាព និងលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញការងារសំរាប់ខេត្តសៀមរាប ដែលជាក្រុងមួយយ៉ាងពិសេសរបស់ប្រទេសគឺជាការចាំបាច់។

**យុទ្ធសាស្ត្រ ខ : ពង្រឹងអភិបាលកិច្ចរបស់ខេត្តសៀមរាប ដើម្បីឱ្យក្លាយជាផ្នែកដ៏សំខាន់សំរាប់ការគ្រប់គ្រងការអភិវឌ្ឍន៍នៅថ្នាក់មូលដ្ឋាន**

ដើម្បីអនុវត្តផែនការមេដែលបានស្នើឡើង ចាំបាច់ត្រូវពង្រឹងការទទួលខុសត្រូវ និងអំណាចរបស់អភិបាលខេត្តលើការងាររដ្ឋបាលនៅថ្នាក់មូលដ្ឋាន។ ពង្រាងច្បាប់អង្គការកំពុងតែត្រូវបានរៀបចំដោយក្រសួងមហាផ្ទៃ។ ច្បាប់នេះនឹងត្រូវការរយៈពេល៣ ឆ្នាំ ឬយូរជាងនេះដើម្បីអនុម័តឱ្យប្រើប្រាស់។

**យុទ្ធសាស្ត្រ គ : ធានាឱ្យមានថវិកាគ្រប់គ្រាន់សំរាប់រដ្ឋបាលឯកភាព**

រដ្ឋបាលឯកភាពរបស់ខេត្តសៀមរាបចាំបាច់ធានាឱ្យមានថវិកាផ្ទាល់ខ្លួនដោយការបង្កើតប្រព័ន្ធពន្ធថ្មី និងបង្កើនចំណូលពន្ធនៅមូលដ្ឋាន។ នៅក្នុងបរិបទនៃកំណែរទំរង់ អភិបាលខេត្តត្រូវមានតួនាទីជាម្ចាស់ដើមនៃថវិការបស់មន្ទីរនានានៅក្នុងខេត្ត។ ផ្ទុយទៅវិញ តាមការអនុវត្តជាក់ស្តែង គេត្រូវការពេលវេលាច្រើនយ៉ាងដើម្បីធ្វើឱ្យសំរេចលើកំណែទំរង់ហិរញ្ញវត្ថុនៅមូលដ្ឋាន។

**យុទ្ធសាស្ត្រ ឃ : បង្កើតប្រព័ន្ធប្រជាធិបតេយ្យអាស្រ័យសភា ដើម្បីធានាឱ្យបាននូវតម្លាភាព និងគណនេយ្យភាពនៅថ្នាក់ខេត្ត**

បើតាមក្របខ័ណ្ឌយុទ្ធសាស្ត្រនៃឯកសារកំណែទំរង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ខេត្ត និងស្រុកនឹងត្រូវបង្កើតឡើង ដោយផ្អែកលើគោលការណ៍ប្រជាធិបតេយ្យសេរី ដើម្បីធានាឱ្យបាននូវតម្លាភាព និងគណនេយ្យភាព តាមរយៈការបោះឆ្នោតមិនផ្ទាល់នៅទូទាំងប្រទេស។ ប្រព័ន្ធក្រុមប្រឹក្សានឹងត្រូវបានរៀបចំបន្ទាប់ពីច្បាប់អង្គការត្រូវបានអនុម័តរួច។ ការអនុវត្តន៍តាមប្រព័ន្ធនេះ និងការធានាតម្លាភាព និងគណនេយ្យភាពគឺជាការចាំបាច់។

**យុទ្ធសាស្ត្រ ង : បង្កើតក្របខ័ណ្ឌច្បាប់សំរាប់គាំទ្រដល់រដ្ឋបាលឯកភាព**

ចាំបាច់ដើម្បីបង្កើត និងអនុម័តក្របខ័ណ្ឌច្បាប់សំរាប់គាំទ្ររដ្ឋបាលឯកភាព។ មានច្បាប់ និងក្រឹត្យច្បាប់ជាច្រើនដែលមានទំនាក់ទំនងខ្លាំងជាមួយនឹងការគ្រប់គ្រងរដ្ឋបាលមូលដ្ឋាន ដែលពុំអាចដំណើរការដូចការរំពឹងទុកឡើយ ដូចជាអនុក្រឹត្យសំរាប់ចុះបញ្ជី សណ្ឋាគារ និងយានយន្តជាដើម។

### ៧.១.៣ អនុសាសន៍

### ១. បង្កើតគណៈកម្មាធិការអភិវឌ្ឍន៍ខេត្ត

គណៈកម្មាធិការអភិវឌ្ឍន៍ខេត្តសៀមរាបត្រូវតែបង្កើតដោយផ្អែកលើ"យុទ្ធសាស្ត្រ កៈ រដ្ឋបាលឯកភាព និងយុទ្ធសាស្ត្រ ឃ : តម្លាភាព "។ គោលបំណងរបស់គណៈកម្មាធិការនេះគឺដើម្បី (១)តាមដាន វាយតម្លៃ និងអនុម័តគំរោងអភិវឌ្ឍន៍ដែលបានស្នើសុំ (ដោយរួមបញ្ចូលទាំងគំរោងសប្បទានផង) (២)សំរបសំរួលជាមួយក្រសួង និងភ្នាក់ងារផ្តល់ជំនួយនានាដែលទាក់ទងនឹងគំរោងក្នុងខេត្តសៀមរាប និង(៣)ធានាឱ្យបាននូវតម្លាភាពនៅរាល់នីតិវិធី សំរាប់ការអនុម័តគំរោង។

រចនាសម្ព័ន្ធចាត់តាំងរបស់គណៈកម្មាធិការមានបង្ហាញក្នុងរូបទី៦៣ ខាងក្រោម ។

មានវិធានការមួយចំនួនដែលគណៈកម្មាធិការអាចជួយសម្របសម្រួល និងពង្រឹងក្នុងការអនុវត្តនីតិការងារ ។ ឧទាហរណ៍ មានការព្យាយាមជាបន្តបន្ទាប់ដើម្បីពង្រឹងការផ្តួចផ្តើមគំនិតរបស់អភិបាលខេត្ត ដើម្បីការអភិវឌ្ឍន៍ ដូចជាការផ្តួចផ្តើមគំនិតឱ្យមាន "សេវាកម្មច្រកចេញចូលតែមួយ" ការអនុម័តគម្រោងដែលមានទុនតិចជាង២ លានដុល្លារ កិច្ចប្រជុំអន្តរមន្ទីរ ដើម្បីកែលំអបរិស្ថានក្រុង និងកិច្ចប្រជុំអន្តរមន្ទីរ ដើម្បីបង្កើនប្រសិទ្ធភាពរដ្ឋបាលមូលដ្ឋាន ។

ស្របគ្នានឹងវិធានការនេះ អភិបាលខេត្តអាចរៀបចំគណៈកម្មការ ដែលមានសមាជិកមកពីអន្តរមន្ទីរ និងអាជ្ញាធរអប្សរាដើម្បីឱ្យពួកគេចែករំលែកបទពិសោធន៍ និងគម្រោងដែលបានស្នើសុំនៅក្នុងខេត្ត ។ គណៈកម្មការនេះក៏ជួយលើកទឹកចិត្តឱ្យមានការយល់ដឹងរួមអំពីស្ថានភាពបច្ចុប្បន្ន និងបញ្ហាអភិវឌ្ឍន៍ក្នុងខេត្ត ។ នៅក្នុងគណៈកម្មការនេះ គួរមានសមាជិកជាទីប្រឹក្សាមកពីក្រសួងពាក់ព័ន្ធ ភ្នាក់ងារផ្តល់ជំនួយអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងសហគមន៍ជំនួញ ។




**រូបទី ៦៣ : ពង្រាងរចនាសម្ព័ន្ធរបស់គណៈកម្មការអភិវឌ្ឍន៍ខេត្ត**